ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា

# THE CURRENT LABOR MARKET NEEDS IN CAMBODIA

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា

THE CURRENT LABOR MARKET NEEDS IN CAMBODIA

សាស្ត្រាចារ្យណែនាំ៖ សុខ ឡៃហុក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទ៖ តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា**

| | |
|---|---|
| គណៈកម្មការវាយតម្លៃទី១ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត ស្រេង ផល្លា | សុខ ឡៃហុក |
| គណៈកម្មការវាយតម្លៃទី៣ | គណៈកម្មការវាយតម្លៃទី២ |
| បេក្ខបណ្ឌិត យ៉ាក វុទ្ធី | បេក្ខបណ្ឌិត មាស សំណាង |
| ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ | គណៈកម្មការវាយតម្លៃទី៤ |
| បណ្ឌិត សេង សំអឿន | បេក្ខបណ្ឌិត យ៉ែម សុខហៀក |
| **នាយកវិទ្យាស្ថាន** | នាយិការងអចិន្ត្រៃយ៍ |
| **បណ្ឌិត ហេង វ៉ាន់ដា** | បណ្ឌិត ហ៊ូ គុជគន្ធលីនណា |

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំ សិក្សារួចមកក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារការងារនាពេលបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តីឬអង្គការក្រៅរដ្ឋាភិបាលក្តី ពិតជាត្រូវការជំនាញនេះជាចាំបាច់ផងដែរ ។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថានវ៉ាន់ដាបានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងតម្រូវការការងារផ្សេងៗ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤ ។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់កាន់តែច្បាស់ពីជំនាញដែលកំពុងសិក្សានិងយល់ដឹងអំពីតម្រូវការការងារក្នុងពេលបច្ចុប្បន្ននិងពេលអនាគតពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការមានតម្រូវការការងារនីមួយៗ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះពិតជាមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់យល់ដឹងកាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការសិក្សារពីតម្រូវការការងារនៅកម្ពុជា ។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



តួច ម៉ូនីកា
ID: B21/942



ញាំ សូជានីតា
ID: B21/925



ហេង ស្រីវ៉ាន់
ID: B21/2300



ស៊ាម ស៊ីណាត
ID: B21/920

# សេចក្ដីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ

***សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ***

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្ដែងនូវការគោរពនិងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណដែលបានផ្ដល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ដាសាស្រ្ដាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្ដុះបណ្ដាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្ដល់ទីកន្លែងបណ្ដុះបណ្ដាល ព្រមទាំងផ្ដល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្រ្ដាចារ្យ **សុខ ឡៃហុក** ជាសាស្រ្ដាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្ដាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះផងដែរក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបប្រទះតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន" នេះគឺជាស្នាដៃរបស់ក្រុម នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. .............. ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្ដីសង្ខេបសារណា

នៅក្នុងប្រទេសកម្ពុជា បច្ចុប្បន្នបានបង្កើតសមត្ថភាពរបស់ប្រជាពលរដ្ឋ និងតម្រូវការទីផ្សារការងារនៅកក្នុងប្រទេសឱ្យប្រសើរឡើងពឹងផ្អែកលើការអប់រំ បណ្តុះបណ្តាល និងវគ្គបំប៉ន។ ១.តើនៅប្រទេសកម្ពុជាមានវិស័យណាខ្លះដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេ? ២.តើរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងមានការអភិវឌ្ឍដល់ទីផ្សារការងារសំខាន់យ៉ាងដូចម្តេច?

១.តម្រូវការទីផ្សារការងារបច្ចុប្បន្នក្នុងប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយវិស័យចំនួន១០ ប៉ុន្តែវិស័យដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេនៅកម្ពុជាមាន៤គឺៈ 1.វិស័យសុខាភិបាល 2.វិស័យអប់រំ និងបណ្តុះបណ្តាល 3.វិស័យកសិកម្ម 4.វិស័យឧស្សាហម្ម កាត់ដេរសំលៀកបំពាក់និងផលិតស្បែកជើង។ ហើយវិស័យទាំងអស់នេះហើយបានផ្តល់នូវហិរញ្ញវត្ថុទៅដល់បុគ្គលិកនិងកម្មករដើម្បីឱ្យជីវភាពរបស់ពួកគេមានការរីកចម្រើន។ ២. រាជរដ្ឋាភិបាលបានដាក់ចេញ នូវសូចនាករកម្រិតយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សុវត្ថិភាព និងសុខភាពការងារការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមរមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ។ ពង្រីកវិសាលភាពសេវាមុខរបរ និងការងារដោយបង្កើតមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ថែមចំនួន៦កន្លែង និងមានការជំរុញឱ្យក្រុមហ៊ុននិងអង្គភាពផ្សេងៗ បង្កើតពិព័រណ៌ការងារដែលបើកឱកាសប្រជាពលរដ្ឋទទួលបានការងារសមស្រប។

បើយោងទៅតាមការសិក្សាស្រាវជ្រាវ លើប្រធានបទតម្រូវការទីផ្សារការងារបច្ចុប្បន្ននៅកម្ពុជា ក្រុមយើងខ្ញុំបានសង្កេតឃើញថា កម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ជាក់ស្តែងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានជួយលើកកម្ពស់លក្ខខណ្ឌការងារ និងជំនាញផលិតភាពការងារដើម្បីឱ្យយុវជនមានសមត្ថភាពក្នុងការប្រកួតប្រជែង។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋកម្ពុជាដែលមានចំណេះដឹងនិងអាចប្រើប្រាស់ជំនាញរបស់ខ្លួន ដើម្បីបង្កើតជាប្រយោជន៍សម្រាប់ខ្លួនឯង និងសង្គមជាតិផងដែរ។ តាមការសន្និដ្ឋានខាងលើយុវជន ជាពិសេសនៅតាមជនបទដាច់ស្រយាលឱ្យទទួលបានការសិក្សារៀនសូត្រនិងបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ។

# អក្សរកាត់

| | |
|---|---|
| AMRO | : ASEAN+3 Macroeconomic Research Office |
| AKP | : Agent Kampuchea Press |
| AI | : Artificial intelligence |
| ILO | : International Labor Organization |
| TVET | : Technical and Vocational Education and Training |
| E Commerce | : E-commerce (electronic commerce) |
| ICT | : Information and Communication Technologies |
| IOT | : Internet of Things |
| GMAC | : Graduate Management Admission Council™ |
| GDP | : Gross Domestic Product |
| CATA | : Cambodia Tourism Association |
| NEA | : National Employment Agency |
| MRC | : Mekong River Commission |

# មាតិកា

ទំព័រ


អារម្ភកថា ........ i

រចនាសម្ព័ន្ធ ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបសារណា ........ v


# ជំពូកទី១
# សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់ ........ ៣

១.៤.២ វិសាលភាពនៃកាស្រាវជ្រាវ ........ ៣

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

១.៥.១ វិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងការសរសេរ ........ ៣

១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ ........ ៣

១.៦ សារសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


# ជំពូកទី២
# តម្រូវការទីផ្សារការងារ


២.១ លក្ខណៈទូទៅនៃតម្រូវការទីផ្សារការងារ ........ ៥

២.១.១ និយមន័យ ........ ៥

២.១.២ ទ្រឹស្តីតម្រូវការការរស់នៅនាពេលបច្ចុប្បន្ន ........ ៥

១.តម្រូវការផ្នែក សរីរវិទ្យា ........ ៥

២. តម្រូវការ ផ្នែកសុវត្ថិភាព ........ ៦

៣. តម្រូវការផ្នែកសេចក្តីស្រឡាញ់ និង ភាពជាកម្មសិទ្ធិ ........ ៦

៤. តម្រូវការនៃភាពពេញចិត្តនិងការគោរព ខ្លួនឯង ........ ៦

៥. តម្រូវការនៃការសម្រេចបំណង ........ ៦

២.២ វិស័យដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេនៅកម្ពុជា ..................................................... ៧
២.២.១ និយមន័យ.................................................................................................................... ៧
២.២.២ ប្រវត្តិនិងការវិវត្តន៍របស់ទីផ្សារ ........................................................................................ ៧
២.២.៣ ទ្រឹស្តីទីផ្សាររីកចម្រើននាពេលបច្ចុប្បន្ន ................................................................................. ៧
២.៣ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍ដល់ទីផ្សារការងារ.................................. ៨
២.៣.១ និយមន័យ .................................................................................................................. ៨
២.៣.២ ប្រវត្តិក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ................................................................... ៨
២.៣.៣ ប្រវត្តិនិងការវិវត្តន៍របស់ការងារនៅកម្ពុជា......................................................................... ៩
២.៣.៤ ទ្រឹស្តីនៃការងារ...........................................................................................................១៤

# ជំពូកទី៣

# តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា

៣.១ ស្ថានភាពទូទៅនៃទីផ្សារការងារ..........................................................................................១៥
៣.១.១ គោលនយោបាយ ..........................................................................................................១៥
៣.១.២ បេសកកម្ម និងចក្ខុវិស័យ ..............................................................................................១៦
៣.២ វិស័យដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេនៅកម្ពុជា .............................................១៨
៣.២.១ វិស័យសំខាន់ៗនាពេលបច្ចុប្បន្ននៅកម្ពុជា ........................................................................១៩
១. វិស័យសុខាភិបាល.................................................................................................... ២០
២. វិស័យអប់រំ និងបណ្តុះបណ្តាល..................................................................................... ២១
៣. វិស័យកសិកម្ម..........................................................................................................២២
៤. វិស័យឧស្សាហកម្ម កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង.................................... ២៤
៣.២.២ អនុសាសន៍របស់លោកឯកឧត្តម អ៊ិត សំហេង ................................................................... ២៥
៣.២.៣ អនុសាសន៍របស់លោក ថោង ខុន..................................................................................... ២៦
៣.៣ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍន៍ទីផ្សារការងារ ................................... ២៨
៣.៣.១ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ........................................................................... ២៨
៣.៣.២ ការអភិវឌ្ឍទីផ្សារការងារ ............................................................................................. ៣០

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.........................................................................................................៣២
៤.២ ការវិភាគលើចំណុចខ្សោយ .....................................................................................................៣២

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ............................................................ ៣៤
៥.២ ការផ្តល់អនុសាសន៍ ............................................................ ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បណ្តាប្រទេសនីមួយៗ តែងតែមានការអភិវឌ្ឍផ្សេងៗគ្នា ដែលវិវត្តន៍ទៅតាមសម័យកាលពីមួយទៅមួយ តាមគោលដៅរបស់ថ្នាក់ដឹកនាំ ដើម្បីឱ្យប្រទេសមានការរីកចម្រើនទៅមុខឥតឈប់ឈរ។ ជាក់ស្តែងប្រទេសកម្ពុជានៅក្នុងកំឡុងឆ្នាំ១៩៥៣ដល់១៩៧០ ជាដំណាក់កាលពិសេសមួយក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ព្រះបាទនរោត្តម សីហនុ ប៉ុន្តែផ្ទុយទៅវិញសម័យកាលបន្ទាប់មកទៀតមានការវិនាសកម្មនៃការធ្វើរដ្ឋប្រហាររបស់ លន់ នល់ និងសង្គ្រាមឆាបឆេះឡើងបណ្តាលឱ្យប្រទេសមានការធ្លាក់ដុនដាបជាខ្លាំង។ តែចាប់តាំងពីថ្ងៃទី ០៩ វិច្ឆិកា ១៩៧៩ មកទល់សព្វថ្ងៃនេះប្រទេសកម្ពុជាងើបឡើងពីសង្គ្រាមបណ្តាលឱ្យមានការរីកចម្រើនស្ទើរគ្រប់វិស័យដូចជាវិស័យអប់រំ វិស័យសុខាភិបាល វិស័យទេសចរណ៍ វិស័យទូរគមនាគមន៍ និងវិស័យផ្សេងៗជាច្រើនទៀត។ ដូច្នេះហើយទើបធ្វើឱ្យប្រទេសយើងសព្វថ្ងៃមានវត្តមានលើឆាកអន្តរជាតិ និងមានការអភិវឌ្ឍដោយឥតឈប់ឈរ។

ដោយសារតែមានការរៀបចំដោយ មានរបៀបរៀបរយពីសំណាក់ថ្នាក់ដឹកនាំ ទើបធ្វើឱ្យប្រទេសមានសន្តិភាពជាបន្តបន្ទាប់រហូតមកដល់សព្វថ្ងៃ។ បច្ចុប្បន្ននេះប្រទេសមានភាពសុខសាន្តទើបបណ្តាលឱ្យរាជរដ្ឋាភិបាលមានតម្រូវការការងារជាច្រើនដែលមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការជួយឱ្យប្រជាជនដែលរស់នៅក្នុងប្រទេសកម្ពុជាមានការងារធ្វើគ្រប់គ្នានិងជួយដល់សង្គមជាតិថែមទាំងមិនប្រកាន់អំពីភេទ ពូជសាសន៍ ពណ៌សម្បុរអ្វីឡើយគឺពឹងផ្អែកទៅលើសមត្ថភាពនៃការប៉ិនប្រសព្វជាមួយពហុជំនាញរៀងៗខ្លួន ហើយរៀនយល់ដឹងអំពីវាឱ្យបានល្អប្រសើរដើម្បីយកទៅអនុវត្តជាប្រចាំថ្ងៃនិងអភិវឌ្ឍន៍ប្រទេសឱ្យកាន់តែរីកចម្រើនទៅមុខឥតស្រាក់ស្រាំ ។ បើយើងងាកមកមើលទីផ្សារការងារនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាមានភាពសម្បូរបែបនូវការងារជាច្រើនដូចជា៖ គណនេយ្យករ សវនករ វិស័យឱជីថល វិស្វករ ព័ត៌មានវិទ្យា វិស្វករគីមី អគ្គិសនី គីមីចំណីអាហារ ស្ថាបត្យករ ទូរគមនាគមន៍ មគ្គុទេសចរណ៍ អ្នកបកប្រែភាសាទូត វិស័យឧស្សាហកម្ម វិស័យសុខាភិបាល វិស័យអប់រំ វិស័យកសិកម្ម...។ ការងារទាំងនេះជាក្បាលម៉ាស៊ីនដឹកនាំប្រទេសទៅកាន់ភាពរីកចម្រើន ហេតុដូចនេះហើយទើបធ្វើឱ្យសេដ្ឋកិច្ចក្នុងប្រទេសមានភាពជឿនលឿនលើគ្រប់វិស័យការងារទាំងអស់ ។

សរុបសេចក្តីមក ការងារនៅក្នុងប្រទេសកម្ពុជាក៏កំពុងមានសន្ទុះកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុផលនាំឱ្យតម្រូវការទីផ្សារការងារមានការកើនឡើង អាស្រ័យហេតុនេះហើយបុគ្គលម្នាក់ៗត្រូវព្យាយាមពង្រឹងចំណេះដឹង ការប៉ិនប្រសព្វនិងជំនាញរៀងៗខ្លួនដើម្បីយកទៅបំពេញមុខជំនាញណាមួយដែលបានរៀបរាប់ខាងលើដែលកំពុងតែមានតម្រូវការធនធានមនុស្សជាច្រើនសម្រាប់ទៅបំពេញការងារទាំងនោះនាពេលបច្ចុប្បន្ន។ ដោយហេតុថា តម្រូវការទីផ្សារការងារពិតជាជួយដល់សេដ្ឋកិច្ចជាតិ និងជួយសម្រួលទៅដល់ភាពគ្មានការងារធ្វើរបស់ប្រជាជនកម្ពុជា យ៉ាងខ្លាំងទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទស្តីអំពី **“តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា”** មកសិក្សាស្រាវជ្រាវនិងស្វែងយល់លម្អិតទៅលើប្រធានបទនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សង្គមបច្ចុប្បន្ន សិស្សានុសិស្សមួយចំនួនធំ ដែលបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ តែងឡើងមកបន្តការសិក្សាថ្នាក់សកលវិទ្យាល័យ ដើម្បីក្រេបជញ្ជក់ចំណេះជំនាញផ្សេងៗ ដែលជាជំនាញស្របនឹងសមត្ថភាពដើម្បីយកទៅបម្រើការងារនាពេលអនាគត។ និស្សិតមួយចំនួនក្រោយពីបានបញ្ចប់ថ្នាក់សកលវិទ្យាល័យពួកគេ ក៏ទទួលបានការងារដែលត្រូវជាមួយនឹងជំនាញ ហើយមួយចំនួនទៀត ក៏មិនត្រូវជំនាញរបស់ពួកគេផងដែរ ជាការពិតណាស់ធនធានមនុស្សចំនួនពីរក្រុមដែលកំពុងមានតម្រូវការជាចំបាច់នាពេលបច្ចុប្បន្ន ហើយក៏ជាតម្រូវការដែលសំខាន់បំផុតនៅក្នុងគ្រោងឆ្អឹងនៃវិស័យការងារ។ ធនធានទាំងនោះរួមមាន ៖

ៜ **ក្រុមមនុស្សទី១** គឺជាក្រុមមនុស្សដែលធ្វើការដោយប្រើកម្លាំងកាយ (ប្រើកម្លាំងពលកម្ម)

ៜ **ក្រុមមនុស្សទី២** គឺជាក្រុមមនុស្សដែលធ្វើការដោយប្រើចំណេះដឹង ជំនាញ ភាពប៉ិនប្រសព្វនិងភាពឆ្នៃប្រឌិតផ្សេងៗ (សំដៅដល់ធនធានមនុស្សដែលឆ្លងកាត់ការអប់រំ)

ដូចដែរយើងបានដឹងហើយថា ប្រទេសកម្ពុជាសព្វថ្ងៃនេះ ទាំងនិយោជិត ទាំងនិស្សិត ដែលបានបញ្ចប់ការសិក្សាគ្រប់កម្រិតថ្នាក់ កំពុងតែស្វែងរកអាជីពការងារ ដែលសមស្របជាមួយសមត្ថភាពព្រមទាំងមានជំនាញដែលបានឆ្លងកាត់ការសិក្សា ក្នុងនោះផងដែរ តម្រូវការការងារមានច្រើនវិស័យផ្សេងៗ ដែលទាក់ទងទៅនឹងចំណេះជំនាញ សមត្ថភាព។ ហេតុនេះហើយ ទើបយើងត្រូវសិក្សាយល់ដឹងទៅលើកត្តាផ្សេងៗដែលរាំងស្ទះមិនដំណើរការ និងការរីកចម្រើនបន្ថែមទៀតហើយក្នុងនោះក៏មានសំណួរចោទសួរថា ៖

១.តើនៅប្រទេសកម្ពុជាមានវិស័យណាខ្លះដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេ?

២.តើរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងមានការអភិវឌ្ឍដល់ទីផ្សារការងារយ៉ាងដូចម្តេច?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាអំពីតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជាគឺ មានគោលបំណងផ្តោតសំខាន់ទៅលើវិស័យការងារតែមួយគត់ ដែលជាវិស័យដ៏សំខាន់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ សង្គម និងប្រជាជនឱ្យមានការរីកចម្រើន ។ ជាហេតុធ្វើឱ្យមានគោលបំណងជាច្រើនទាក់ទងទៅនឹងតម្រូវការទីផ្សារការងារនេះឡើងគឺរួមមាន ៖

- សិក្សាស្វែងយល់ពីស្ថានភាពទូទៅនៃទីផ្សារការងារនាពេលបច្ចុប្បន្ន
- សិក្សាស្វែងយល់ពីគោលការណ៍របស់ទីផ្សារការងារ
- សិក្សាស្វែងយល់ពីការអនុវត្តការងារជាក់ស្តែង។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាមានវិស័យការងារជាច្រើន ហើយក៏មានការងារខ្លះអន់ថយ ការងារខ្លះទៀតក៏មានការរីកចម្រើនកើនឡើងជាបន្តបន្ទាប់ ហើយមួយវិញទៀតប្រជានបទក៏មានភាពទូលំទូលាយខ្លាំងដែរជាហេតុនាំឱ្យពួកយើងមិនអាចបកស្រាយបានល្អឥតខ្ចោះ និងបានក្បោះក្បាយបានឡើយ។ ដោយសារតែពេលវេលាមានចំនួនតិចតួច និងឯកសារមានមិនគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវឱ្យដំណើរការទៅបានរលូនទើបធ្វើឱ្យពួកយើងត្រូវពឹងផ្អែកទៅលើ ទំហំដែនកំណត់ និងវិសាលភាព។

#### ១.៤.១ ទំហំដែនកំណត់

នៅក្នុងប្រធានបទនៃការស្រាវជ្រាវនេះ ក្រុមយើងខ្ញុំសូមលើកយកតែទៅលើទីផ្សារការងារណា ដែលកំពុងរីកលូតលាស់និងជាតម្រូវការទីផ្សារចាំបាច់នៅក្នុងប្រទេសកម្ពុជាយកមកសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

#### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដោយផ្អែកទៅលើប្រធានបទនៃការស្រាវជ្រាវ គឺមានវិសាលភាពផ្តោតសំខាន់ទៅលើតែប្រធានបទដែលនិយាយអំពីតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ២០២២តែប៉ុណ្ណោះ។

### ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្រុមយើងខ្ញុំបានយកមកវិភាគគិតត្រិះរិះឱ្យបានគ្រប់ជ្រុងជ្រោយអំពីឯកសារ ឬរបាយការណ៍ដែលបានស្រាវជ្រាវ និងប្រមូលទិន្នន័យមានដូចខាងក្រោម ៖

#### ១.៥.១ វិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងការសរសេរ

ដើម្បីឱ្យការសិក្សាទៅលើប្រធានបទ និងការវិភាគទៅលើទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជាបញ្ចប់ទៅដោយភាពជោគជ័យក្រុមយើងខ្ញុំទាំងអស់គ្នាបានប្រមូលព័ត៌មានសំខាន់ៗតាមរយៈមធ្យោបាយដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធឺណេត និងវេបសាយផ្សេងៗ
- ឯកសារស្រាវជ្រាវរបស់សិស្សច្បងជំនាន់មុន និងតាមសកលវិទ្យាល័យ ឬវិទ្យាស្ថានផ្សេងៗ
- ឯកសារបន្សល់ទុកនៅតាមបណ្ណាល័យ ឬបណ្ណាគារ
- សិក្សា និងសាកសួរនូវព័ត៌មានឬឯកសារទាំងឡាយពីសំណាក់លោកគ្រូ អ្នកគ្រូនិងសាស្ត្រាចារ្យណែនាំបន្ថែម។

#### ១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ទិន្នន័យដែលយើងបានប្រមូលនិងរកបានមកពីប្រភពមួយចំនួនដូចជា ៖

- ឯកសារស្រាវជ្រាវតាមរយៈអ៊ីនធឺណេត
- ស្រាវជ្រាវនៅតាមបណ្ណាល័យ ឬបណ្ណាគារ
- តាមរយៈឯកសារដែលបានសិក្សាកន្លងមកនៅវិទ្យាស្ថានវ៉ាន់ដា។

### ១.៦ សារសំខាន់នៃការស្រាវជ្រាវ

–ធ្វើឱ្យយើងយល់ដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃតម្រូវការទីផ្សារការងារ

–ធ្វើឱ្យយើងចេះបំពេញនូវចំណុចដែលខ្វះខាតដែលយើងបានរៀនសូត្រកន្លងមក

–ធ្វើឱ្យយើងបានចេះស្រាវជ្រាវ រៀបចំ ហើយក៏បានចងក្រងជាឯកសារ

–ធ្វើឱ្យយើងបានយល់ដឹងពីរបៀបធ្វើការជាក្រុម

–ធ្វើឱ្យយើងទទួលបានចំណេះដឹងកាន់តែច្រើន

–ធ្វើឱ្យយើងយល់ច្បាស់ពីតម្លៃនៃការងារ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

➢**ជំពូកទី១ សេចក្តីផ្តើម៖** គឺបានបង្ហាញពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ។

➢**ជំពូកទី២ រំលឹកទ្រឹស្តី** ៖ បានលើកឡើងពីទ្រឹស្តីដែលពាក់ព័ន្ធ ទស្សនទាន ឬសំដីរបស់អ្នកប្រាជ្ញ និងបទពិសោធន៍ផ្សេងៗទៀត។

➢**ជំពូកទី៣ លទ្ធផលនៃការស្រាវជ្រាវ** ៖ លើកឡើងពីស្ថានភាពទូទៅរបស់អង្គភាពដូចជា ប្រវត្តិរបស់អង្គភាព បេសកកម្ម ទស្សនវិស័យ គោលនយោបាយ រចនាសម្ព័ន្ធចាត់តាំង (តួនាទី និងភារកិច្ច) និងបន្ទាប់មានការលើកឡើងបានពីរ ឬបីចំណុចទៅលើការងារបច្ចេកទេសរបស់អង្គភាព។

➢**ជំពូកទី៤ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ ៖** ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយគឺវិភាគទៅលើចំណុចទាំងអស់ ដែលបានអនុវត្តន៍ជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣) គឺក្នុងគោលបំណង វិភាគឱ្យឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីធ្វើការកែលម្អ។

➢**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ៖** សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ គឺធ្វើការសិន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលំអ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# តម្រូវការទីផ្សារការងារ

## ២.១.លក្ខណៈទូទៅនៃតម្រូវការទីផ្សារការងារ

### ២.១.១. និយមន័យ

**តម្រូវការ** គឺជាការចង់បានឬបំណងប្រាថ្នាចង់បានរបស់ល្អឬសេវាកម្ម ដែលមានទំនិញសេវាកម្មឬឧបករណ៍ដែលចាំបាច់ដើម្បីធ្វើប្រតិបត្តិការស្របច្បាប់សម្រាប់ទំនិញឬសេវាកម្មទាំងនោះ[1]។

**តម្រូវការ** គឺជាបំណងដែលអ្នកទិញ ចង់ទិញ ឬចង់បាននូវទំនិញ ឬលោកម្ម និងមានលទ្ធភាពទិញបាននៅក្នុងពេលមួយដ៏ជាក់លាក់ និងក្នុងលក្ខខណ្ឌដែលកត្តាដទៃទៀតមិនផ្លាស់ប្តូរ[2]។

### ២.១.២. ទ្រឹស្តីតម្រូវការការរស់នៅនាពេលបច្ចុប្បន្ន

ឋានានុក្រមនៃតម្រូវការ **Ma slow (Ma slow hierarchy of needs)** គឺជាទ្រឹស្តី លើកទឹកចិត្តរបស់លោកA braham Ma slow មាន៥កម្រិតផ្សេងៗគ្នាដូចជា តម្រូវការ ផ្នែកសរីរវិទ្យា ( Physiological need ) តម្រូវការផ្នែកសុវត្ថិភាព ( Safety needs ) តម្រូវការ សេចក្តីស្រឡាញ់និងភាពជាកម្មសិទ្ធិ(Be longing ness and love needs) តម្រូវការនៃភាពពេញចិត្តនិងការគោរពខ្លួនឯង(Self-esteem needs) និងតម្រូវការនៃការសម្រេចបំណង (Self - actualization )។

ទ្រឹស្តីនេះអាចប្រើប្រាស់បានច្រើនកាលៈទេសៈហើយប្រើប្រាស់តាមរបៀបខុសគ្នាអាស្រ័យលើអ្នកយកវាទៅអនុវត្តគ្រាន់តែវាអាស្រ័យទៅលើរបៀបដែលគេបកស្រាយក្នុងការប្រើប្រាស់ថ្វីដ្បិតថាអត្ថន័យនៃទ្រឹស្តីនេះមានភាពទូលំទូលាយនិងអាចបំបែកន័យបានផ្សេងៗគ្នា។ នៅក្នុងផ្នែកហិរញ្ញវត្ថុផ្ទាល់គេអាចប្រើប្រាស់ទ្រឹស្តីនេះក្នុងជីវភាពប្រចាំថ្ងៃដូចខាងក្រោម ៖

**១ . តម្រូវការផ្នែក សរីរវិទ្យា**

បើយោងទៅតាមទ្រឹស្តី លោក **Ma slow** តម្រូវការផ្នែកសរីរវិទ្យា សំដៅទៅលើតម្រូវការចាំបាច់របស់មនុស្សម្នាក់ៗមានដូចជាម្ហូបអាហារ កន្លែងស្នាក់នៅ ប្រាក់សម្រាប់ការចាយវាយលើបញ្ហាសុខភាពជាដើម។ នោះបានន័យថាមនុស្សម្នាក់ៗត្រូវការលំហូរសាច់ប្រាក់មួយ ស្ថេរភាពសិនដើម្បីទប់ទល់នឹងការចាយវាយលើតម្រូវការចាំបាច់ទាំងនេះមុននឹងមានតម្រូវការចាយវាយផ្សេងៗទៀត។ ដើម្បីឱ្យការចាយវាយទទួលបានប្រសិទ្ធភាពអ្នកគួរ បង្កើតជាគម្រោងចាយវាយប្រចាំខែនិង តាមដានរបាយការណ៍ចាយវាយរបស់អ្នកឱ្យបានទៀងទាត់ ។

---

[1]https://km.eferrit.com/%E1%9E%93%E1%9E%B7%E1%9E%99%E1%9E%98%E1%9E%93%E1%9F%90%E1%9E%99%E1%9E%93%E1%9F%83%E1%9E%8F%E1%9E%98%E1%9F%92%E1%9E%9A%E1%9E%BC%E1%9E%9C%E1%9E%80%E1%9E%B6%E1%9E%9A/

[2]https://www.facebook.com/photo.php ?fbid=306826824340426&set=a.113338037022640&type=3&paipv=0&eav=Afb06L7G5mAkVhEQbepNwCEqQH_VmfPvSefgkSkEWmbxYFPjNRaBMr2_ogHx0bc_qDk&_rdr

## ២ . តម្រូវការ ផ្នែកសុវត្ថិភាព

បន្ទាប់ពីអាចគ្រប់គ្រងលើតម្រូវការចាំបាច់ បានរួចហើយតម្រូវការបន្ទាប់របស់យើងម្នាក់ៗ គឺតម្រូវការ ផ្នែកសុវត្ថិភាព មានន័យថាមនុស្សម្នាក់ត្រូវការ ការគាំពារ ផ្នែកសុខភាព រូបរាងកាយ និង ផ្លូវចិត្ត ក៏ដូចជាការការពារពីច្បាប់ក្នុងប្រទេស។ ដើម្បីសម្រេចបានតម្រូវការ ផ្នែកសុវត្ថិភាពនេះយើងម្នាក់ៗរមែងគួរមានគម្រោងប្រាក់សន្សំសម្រាប់គ្រាមានអាសន្នក៏ដូចជាការទិញនូវសេវាកម្ម ធានារ៉ាប់រងដើម្បីការពារពីហានិភ័យណាមួយកើតឡើងដោយយើងមិនអាចគ្រប់គ្រងបាន។

## ៣ . តម្រូវការផ្នែកសេចក្តីស្រឡាញ់ និង ភាពជាកម្មសិទ្ធិ

ក្នុងទ្រឹស្តីរបស់លោក**Ma slow** តម្រូវការផ្នែកសេចក្តីស្រឡាញ់និងភាពជាកម្មសិទ្ធិសំដៅទៅលើតម្រូវការសេចក្តីស្រឡាញ់ដែលបានមកពីគ្រួសារមិត្តភក្តិនិងមនុស្សជាទីស្រឡាញ់របស់ខ្លួនក៏ដូចជាតម្រូវការថាខ្លួនក៏ជាសមាជិកម្នាក់នៃក្រុមណាមួយ ។ នៅពេលដែលនរណាម្នាក់ខ្វះសេចក្តីស្រឡាញ់ទាំងនេះធ្វើឱ្យពួកគាត់មានអារម្មណ៍ថាឯកោឬរហូតដល់មានជំងឺបាក់ទឹកចិត្តជាដើម។ដូចនេះ មនុស្សម្នាក់ៗត្រូវការកម្លាំងចិត្តដើម្បីសម្រេចអ្វីមួយឬបើក្នុងផ្នែកហិរញ្ញវត្ថុក្នុងដំណាក់កាលនេះសំដៅទៅលើតម្រូវការដែលអ្នកការគាំទ្រពីមនុស្សជុំវិញខ្លួនលើការវិនិយោគលើវិស័យណាមួយការគិតគូរ ពីការសន្សំប្រាក់សម្រាប់ចូលនិវត្តន៍ក៏ដូចជាព្យាយាមដោះស្រាយបំណុលឱ្យរួចស្រេចជាដើម។

## ៤ . តម្រូវការនៃភាពពេញចិត្តនិងការគោរពខ្លួនឯង

ឈានជើងមួយកម្រិតទៀតនៃឋានានុក្រមនៃតម្រូវការរបស់លោក **Ma slow** គឺជាដំណាក់កាលនៃតម្រូវការការទទួលស្គាល់ពីមនុស្សជុំវិញខ្លួនតាមរយៈមុខតំណែងការគោរពពីមនុស្សជុំវិញខ្លួនក៏ដូចជាការគោរពខ្លួនឯងតាមរយៈការពេញចិត្តនូវអ្វីដែលខ្លួនកំពុងមានជាដើម។ បើយើងនិយាយពីតម្រូវការផ្នែកហិរញ្ញវត្ថុវិញក្នុងដំណាក់កាលនេះមនុស្សម្នាក់ៗ អាចគ្រប់គ្រងលើចំណូល ចំណាយចាំបាច់បានហើយថែមទាំងអាចមានប្រាក់សន្សំសម្រាប់ចូលនិវត្តន៍ប្រាក់សម្រាប់កូនៗសិក្សាឬអាចនិយាយបានថាយើងអាចសម្រេចបានសេរីភាពហិរញ្ញវត្ថុបានហើយ ។

## ៥ . តម្រូវការនៃការសម្រេចបំណង

ចំណុចចុងក្រោយនេះសំដៅលើការរៀបចំផ្ទេរមរតកដែលខ្លួនមានទៅកាន់គ្រួសារ ឬ សង្គមជាតិ។ ក្នុងចំណុចនេះមានន័យថាអ្នកប្រហែលជាចង់ចែកទ្រព្យសម្បត្តិអ្នកឬបន្ទាប់ពីមរណភាពទៅដល់សាច់ញាតិ រដ្ឋាភិបាលនិងមូលនិធិអ្វីមួយដើម្បីជាប្រយោជន៍ក្នុងសង្គមជាដើម ។ ក្រៅពីការផ្ទេរមរតកទៅតម្រូវការមនុស្សម្នាក់ៗក្នុងដំណាក់ទី៥ នេះអាចមានបំណងចង់ក្លាយខ្លួនទៅបុគ្គលណាម្នាក់ដែលគេទទួលស្គាល់ក្នុងសង្គមការចង់សម្រេចបានចំណេះដឹងថ្មីៗបន្ថែមនិងសម្រេចក្តីស្រមៃរបស់ខ្លួនណាមួយដែលធ្លាប់ប៉ងប្រាថ្នាជាយូរមកហើយ។ ការស្វែងយល់អំពីទ្រឹស្តីនេះអាចធ្វើឱ្យយើងស្វែងយល់កាន់តែច្បាស់អំពីការរៀបចំទុកដាក់ផ្នែកហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពស្របតាមដំណាក់កាលនៃតម្រូវការរបស់មនុស្សម្នាក់ៗហើយថែមទាំងអនុញ្ញាតឱ្យយើងម្នាក់ៗមានការគិតបែបស៊ីជម្រៅលើគម្រោងហិរញ្ញវត្ថុថែមទៀតផង [3]។

[3] https://www.kakcent.com/ma%E2%80%8Bslow%E2%80%8B-%E2%80%8Bhierarchy%E2%80%8B-o%E2%80%8Bf%E2%80%8B-%E2%80%8Bneeds/

## ២.២ វិស័យដែលមានតម្រូវការទីផ្សារការងារសំខាន់ជាងគេនៅកម្ពុជា

### ២.២.១ និយមន័យ

ចំពោះនិយមន័យ មានការសិក្សាជាច្រើនបានឱ្យយោបល់ផ្សេងៗគ្នា៖

តាមបែបបុរាណ៖ **ទីផ្សារ** គឺជាកន្លែងដែលស្តែងចេញនូវដំណើរការ ទិញ លក់(ដោះដូរ)ឬជាកន្លែងដែលអ្នកទិញនិងអ្នកលក់ជួបគ្នាដើម្បីទិញលក់ផលិតផល។

តាមបែបទំនើប៖ **ទីផ្សារ** គឺជាសមរភូមិអាជីវកម្មជាកន្លែងដែលអាជីវករ ឬក្រុមហ៊ុនប្រមើលមើលតម្រូវការរបស់សង្គមនិងវាយតម្លៃអាជីវកម្មរបស់ខ្លួន។

**ទីផ្សារ** គឺជាក្រុមអតិថិជនដែលកំពុងមានកម្លាំងទិញ និងមានតម្រូវការដែលមិនទាន់បានបំពេញ។

**ទីផ្សារ** គឺជាបុគ្គលិក ឬអង្គភាពដែលមានតម្រូវការត្រូវបំពេញ មានប្រាក់សម្រាប់ចំណាយ និងមានបំណងក្នុងការចំណាយ[4] ។

### ២.២.២ ប្រវត្តិនិងការវិវត្តន៍របស់ទីផ្សារ

ជាង៣០ឆ្នាំកន្លងមកនេះ យើងសង្កេតឃើញថាមានផ្នែកនៃអ្នកផលិត អ្នកបោះដុំ អ្នកលក់រាយ និងអង្គភាពមិនសំដៅទៅលើប្រាក់ចំណេញទាំងអស់សុទ្ធសឹងតែបានអនុវត្តន៍ទ្រឹស្តីទីផ្សារទំនើបនៅក្នុងអង្គភាពអាជីវកម្មរបស់ពួកគេ។ ពួកគេមិនត្រឹមតែផ្តោតការយកចិត្តទុកដាក់ទៅលើសកម្មភាពផលិតកម្ម និងការលក់ប៉ុណ្ណោះទេថែមទាំងជម្រុញការខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីបំពេញនូវសេចក្តីត្រូវការរបស់អតិថិជនថែមទៀតផង[5]។

### ២.២.៣ ទ្រឹស្តីទីផ្សាររីកចម្រើននាពេលបច្ចុប្បន្ន

ទ្រឹស្តីទីផ្សាររបស់លោក **Porter**:

- Threat of New Entry(កត្តាគំរាមកំហែងពីអ្នកលោតចូលទីផ្សារថ្មី): គឺជាកត្តាខាងក្រៅមួយដែលយើងមិនអាចគ្រប់គ្រងបាន។ ឧទាហរណ៍យើងកំពុងរកស៊ីជោគជ័យលើវិស័យអ្វីមួយស្រាប់តែមានគូប្រកួតដែលមានលុយនិងធនធានខ្លាំងជាងយើងលោតចូលទីផ្សារភ្លាមនោះច្បាស់ណាស់ថាវានឹងប៉ះពាល់ទៅដល់ប្រាក់ចំណេញរបស់យើងជាមិនខាន ហើយគូប្រកួតដែលមានធនធានច្រើនជាងយើងគេនឹងបុកទីផ្សារខ្លាំងជាងយើងជួលកាល អាចនាំឱ្យមានយុទ្ធសាស្ត្របន្ទាបតម្លៃទៀតក៏ថាបាន។

- Supplier Power (កម្លាំងអ្នក ផ្គត់ផ្គង់): នៅពេលដែលយើងមានដៃគូរផ្គត់ផ្គង់កាន់តែច្រើននោះយើងកាន់តែងាយស្រួលផ្លាស់ប្តូរនិងមានជម្រើសច្រើនយ៉ាង។ បើយើងចង់ប្តូរក៏យើងមិនខាតតែបើអ្នកផ្គត់ផ្គង់តិចវិញនោះ ច្បាស់ជាពួកគេអាចក្រឡុកអ្នកបានជាមិនខាន។ អ្នកផ្គត់ផ្គង់តិចអាចបង្វិលតម្លៃបានគ្រប់ពេលហើយច្បាស់ណាស់ថាវានឹងប៉ះពាល់ដល់ប្រាក់ចំណេញរបស់អ្នក[6]។

[4] https://m.facebook.com/banalaineak/posts/382881626610045/?locale=km_KH

[5] https://kohsantepheapdaily.com.kh/

[6] http://thehrdaily.com.dream.website/business/page=123/portersfiveforces/

អ្នកជំនាញមួយរូបក្នុងចំណោមអ្នកជំនាញល្បីល្បាញក្នុងការគ្រប់គ្រងទីផ្សារគឺលោក **Pr.PhilipKotler** បានឱ្យទ្រឹស្តីទៅលើទីផ្សារថា ៖

**ទីផ្សារ** គឺជាការផ្តល់អ្វីដែលជាតម្រូវការរបស់ អតិថិជនដើម្បីទទួលបានផលកម្រៃទៅវិញទៅមកនិងជាដំណើរការរបស់សង្គមមួយដែលក្នុងនោះមានបុគ្គលនិងក្រុមមនុស្សជាច្រើនទទួលបាននូវអ្វីដែលគេត្រូវការ និងចង់បានតាមរយៈការបង្កើតឡើងនិងការដោះដូរគ្នាទៅវិញទៅមករវាងផលិតផល និងសេវាកម្មជាមួយអ្នកដទៃ[7]។

យោងតាម **សមាគមន៍ទីផ្សារអាមេរិក(American Marketing Association)** បានពោលថា៖

**ទីផ្សារ** គឺជាដំណើរការនៃការរៀបចំផែនការនិងការអនុវត្តទ្រឹស្តីការកំណត់តម្លៃការផ្សព្វផ្សាយផលិតផលនិងការចែកចាយគំនិតយោបល់ផលិតផលនិងសេវាកម្មដើម្បីបង្កើតការដោះដូរដែលតម្រូវទៅតាមគោលបំណងរបស់បុគ្គល និងអង្គភាព[8]។

## ២.៣ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍដល់ទីផ្សារការងារ

### ២.៣.១ និយមន័យ

មាននិយមន័យដែលទាក់ទងទៅនឹងការងារជាច្រើនដែលឱ្យន័យដូចខាងក្រោម៖

**ការងារ** គឺជាកិច្ចដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន[9]។

**ការងារ** សំដៅដល់ការងារដែលអ្នកធ្វើវាដើម្បីទទួលបានប្រាក់កម្រៃត្រលប់មកវិញ។អ្នកអាចនឹងមានការងារច្រើនមុខហើយអ្នកធ្វើដោយផ្អែកលើហេតុផលខុសៗពីគ្នាដូចជា មូលហេតុរកប្រាក់កម្រៃសម្រាប់គ្រួសារ សន្សំសម្រាប់ទិញឧបករណ៍សម្ភារៈនានា ឬផ្គត់ផ្គង់ខ្លួនឯងជាដើម[10] ។

**ការងារ** គឺជាសកម្មភាពទាំងឡាយណាដែលមនុស្សធ្វើដើម្បីរកប្រាក់ ។

**ការងារ** ជាការបង្កើតទំនិញឬសេវាកម្មដែលបង្កើតឡើងឬធ្វើអ្វីៗដោយខ្លួនឯងផ្ទាល់ឬក៏លក់កម្លាំងពលកម្មទៅឱ្យនរណាម្នាក់ ។

**ការងារ** គឺសំដៅទៅលើការអនុវត្តកាតព្វកិច្ចទាំងឡាយដែលអាចឱ្យមនុស្សរស់បាននៅក្នុងបរិបទសេដ្ឋកិច្ច និងសង្គមទៅតាមតំបន់ឬទីកន្លែងដែលគេរស់នៅ[11] ។

### ២.៣.២ ប្រវត្តិក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ក្នុងនីតិកាលទី៣ នៃរដ្ឋសភាស្របតាមអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ប៉ុន្តែនៅឆ្នាំ២០១៤ត្រូវបានរៀបចំធ្វើវិសោធនកម្មតាមរយៈអនុក្រឹត្យលេខ២៨៣អនក្រ.បកចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ [12]។

### ២.៣.៣ ប្រវត្តិនិងការវិវត្តន៍របស់ការងារនៅកម្ពុជា

[7] http://wtech-cambodia.weebly.com/marketing.html
[8] http://wtech-cambodia.weebly.com/marketing.html
[9] វចនានុក្រមជួនណាត
[10] https://m.facebook.com/technologyallinonce/photos/a.109641708016712/114022850911931/?type=3&locale=en_GB
[11] http://www.khserch.com/qna/18885
[12] www.mlvt.gov.kh

សមាហរណកម្ម របស់ប្រទេសកម្ពុជាទៅក្នុងតំបន់ និងនៅក្នុងពិភពលោក គឺជាគោលដៅអាទិភាពមួយរបស់រដ្ឋាភិបាល ដើម្បីបំបាត់នូវភាពឯកោរបស់ខ្លួនលើឆាកអន្តរជាតិ។ រាជរដ្ឋាភិបាលបានពុះពារគ្រប់បែបយ៉ាង ប្រកបដោយឆន្ទៈនយោបាយយ៉ាងមោះមុត ដើម្បីធ្វើសមាហរណកម្មកម្ពុជាយើងទៅក្នុងតំបន់ ហើយនៅទីបំផុតប្រទេសកម្ពុជាបានក្លាយទៅជាសមាជិកពេញសិទ្ធិ របស់អាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ ចាប់តាំងពីបានក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ានមក កម្ពុជាបានធ្វើការងារយ៉ាងសកម្មក្នុងការលើកកម្ពស់ទំនាក់ទំនងការទូតនិងធ្វើសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកនៅលើគ្រប់វិស័យមានជាអាទ៍ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម សន្តិសុខ និងនយោបាយ[13]។ ដោយផ្អែកទៅលើការធ្វើសមាហរណកម្មសេដ្ឋកិច្ចតើក្នុងនាមយើងជាប្រជាជនក្នុងប្រទេសដែលជាសមាជិកនេះអាចទទួលបានអត្ថប្រយោជន៍អ្វីខ្លះ?

សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា អាស៊ាន( ASEAN )បង្កើតឡើងនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ នៅទីក្រុងបាងកកប្រទេសថៃ។ ក្នុងគោលដៅឱបក្រសោបបណ្តាប្រទេសនៅក្នុងតំបន់ឱ្យក្លាយជាសមាគមន៍ដ៏រឹងមាំមួយលើវិស័យ សេដ្ឋកិច្ច យោធា និងវប្បធម៌។ ម្យ៉ាងវិញទៀតជួយបង្កើនល្បឿនកំណើនសេដ្ឋកិច្ចវឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់លើកកម្ពស់សន្តិភាពនិងស្ថេរភាពនៅក្នុងតំបន់ ជំរុញកិច្ចសហប្រតិបត្តិការ និងការឧបត្ថម្ភជួយគ្នាទៅវិញទៅមកដោយមិនរំពឹងផលប្រយោជន៍តបស្នងផ្តល់ជំនួញដល់គ្នាទៅវិញទៅមកក្នុងទម្រង់ជាការបណ្តុះបណ្តាល និងការស្រាវជ្រាវឧបករណ៍កិច្ចសហប្រតិបត្តិការដើម្បីធ្វើឱ្យមានភាពល្អប្រសើរ ខាងវិស័យកសិកម្ម និងឧស្សាហកម្ម ដើម្បីលើកកម្ពស់ជីវភាពប្រជាជន លើកកម្ពស់ការសិក្សានៅអាស៊ីអាគ្នេយ៍រក្សាមិត្តភាពដើម្បីប្រយោជន៍នៃកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដែលមានគោលបំណងដូចគ្នា ឬស្រដៀងគ្នា[14] ។ កម្ពុជាជាប្រទេសចុងក្រោយគេដែលបានក្លាយជាសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា អាស៊ាន។សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាអ្នកដែលនាំកម្ពុជាចូលអាស៊ានបានលើកឡើងនូវកត្តាចម្បងបួន ដែលកម្ពុជាចូលជាសមាជិកអាស៊ាន៖ (១).កត្តាមិនជ្រៀតកិច្ចការផ្ទៃក្នុងផងគ្នាទៅវិញទៅមកដែលតាមរយៈនេះអាស៊ានបានក្លាយទៅជារបាំងដ៏សំខាន់សម្រាប់ការពារអធិបតេយ្យនៃរដ្ឋជាសមាជិក(២)កត្តាស្មារតីសហគមន៍គឺរបៀបនៃការធ្វើសេចក្តីសម្រេចចិត្តរបស់អាស៊ានដែលផ្អែកលើគោលការណ៍នៃកុងសង់ស៊ីសគឺសិទ្ធិស្មើរគ្នាក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយមិនគិតថាសមាជិកចាស់ ឬសមាជិកថ្មី ឬប្រទេសអ្នកមាន ប្រទេសអ្នកក្រ (៣).កត្តាសមាហរណកម្មតំបន់ពោលគឺជាស្នូលនៃនិម្មាបនកម្មតំបន់ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម និង( ៤ ). អាស៊ានជាច្រកទ្វារការទូតដ៏សំខាន់សម្រាប់កម្ពុជា។ចាប់តាំងពីកម្ពុជាបានចូលជាសមាជិកអាស៊ាននៅឆ្នាំ ១៩៩៩ មកអាស៊ានតែងតែជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយការបរទេសរបស់កម្ពុជា។ ជាក់ស្តែងគិតត្រឹមឆ្នាំ២០២២ មានរយៈ២៣ឆ្នាំកន្លងមកនេះ កម្ពុជាបានចាប់យកនូវ ឱកាសជាច្រើនពីសមាជិកភាពរបស់ខ្លួននៅក្នុងអាស៊ានហើយកម្ពុជាក៏បានចូលរួមចំណែកយ៉ាងធំធេងផងដែរក្នុងការកសាងសហគមន៍អាស៊ាន និយាយជារួមនិងការកសាងសហគមន៍នយោបាយសន្តិសុខអាស៊ាន។ និយាយដោយឡែកចាប់តាំងពីពេលដែលកម្ពុជាបានក្លាយជាសមាជិកអាស៊ាននៅឆ្នាំ១៩៩៩មកកម្ពុជាធ្លាប់បានធ្វើជាប្រធានអាស៊ានចំនួន២លើករួចមកហើយ គឺលើកទី១នៅឆ្នាំ២០០២ និងលើកទី២នៅឆ្នាំ២០១២ ហើយ

[13] http://library.fes.de/pdf-files/bueros/singapur/04611-03.pdf

[14] http://khmerpostasia.com/archives/30793

នៅឆ្នាំ២០២២ កម្ពុជានឹងធ្វើជាប្រធានអាស៊ានជាថ្មីម្តងទៀត។ ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ តើអ្វីជាឱកាសសម្រាប់កម្ពុជាក្នុងដំណើរការកសាងសហគមន៍នយោបាយសន្តិសុខអាស៊ាន? តើកម្ពុជាគួរត្រៀមលក្ខណៈបែបណាខ្លះដើម្បីចាប់យកឱកាសទាំងនោះ? ជាការពិតណាស់ តួនាទីជាប្រធានអាស៊ាន អាចជាមោទនភាពផងហើយក៏អាចជាសម្ពាធផង ជាឱកាសផង ហើយក៏អាចជាបញ្ហាប្រឈមផងដែរ។ ក៏ប៉ុន្តែជាបឋមអ្វីដែលជាឱកាសសម្រាប់កម្ពុជានៅពេលនេះគឺជាពេលវេលាដែលយើងអាចបង្ហាញប្រកបទៅដោយក្តីមោទនភាពពិតថាកម្ពុជាដែលពីមុនជាប្រទេសមួយដែលត្រូវទទួលរងនូវការហ៊ុមព័ទ្ធនិងឯកោទាំងខាងនយោបាយ និងសេដ្ឋកិច្ចឥឡូវបានក្លាយជាប្រទេសមួយដែលកំពុងមានសមាហរណកម្មខ្លួនយ៉ាងសកម្មនៅក្នុងរចនាសម្ព័ន្ធនិម្មាបនកម្មក្នុងតំបន់និងជាប្រទេសដែលកំពុងតែដើរតួនាទីយ៉ាងសកម្មដោយស្មើរសិទ្ធិ និងស្មើរភាពនៅក្នុងគ្រប់កិច្ចការតំបន់ហើយ និងនៅលើឆាកអន្តរជាតិនិងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ពហុភាគីនិយម[15] ។ ហើយអាស៊ានកំពុងតែឈានដល់ដំណាក់កាលនៃតំបន់ពាណិជ្ជកម្មសេរីដែលបើកកិច្ចសហការរវាងប្រទេសសមាជិក និងប្រទេសមិនមែនជាសមាជិក។គំនិតបង្កើននូវតំបន់ពាណិជ្ជកម្មសេរីត្រូវបានផ្តួចផ្តើមឡើងតាំងពី ឆ្នាំ១៩៩២ ដោយមានវត្តមាននូវគោលការណ៍បន្ធូរបន្ថយពន្ធលើទំនិញនាំចូលរវាងប្រទេសដែលជាសមាជិក និងប្រទេសដែលជាដៃគូរ (Dialogue Partners)។ វិធានការដែលអាស៊ានកំពុងអភិវឌ្ឍន៍នោះគឺដើម្បីពង្រីកនូវទីផ្សារសេរីរបស់អាស៊ាន និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment)។ ប្រទេសជាសមាជិកអាចធ្វើពាណិជ្ជកម្មសេរីជាមួយសមាជិកដូចគ្នា និងជាមួយប្រទេសដែលមិនមែនជាសមាជិក ហើយទទួលបានផលប្រយោជន៍សេដ្ឋកិច្ចជាច្រើនតាមរយៈងារជាសមាជិកអាស៊ាននេះ។ ជាក់ស្តែងប្រទេសកម្ពុជាយើងទទួលបានឱកាសចូលទៅកាន់ទីផ្សារប្រទេសដែលជាដៃគូរពាណិជ្ជកម្មអាស៊ានបានកាន់តែងាយស្រួលដូចជាចិន ជប៉ុន កូរ៉េខាងត្បូង(ASEAN+3 countries)និងប្រទេសដែលជាដៃគូរអាស៊ាន អូស្រ្តាលី ឥណ្ឌា និងណូវែលសេឡង់ (Regional Comprehensive Economic Partnership countries)ឧទាហរណ៍ ការវិនិយោគពីប្រទេសជប៉ុនមានចំនួន២២៤ ៩៩៨ដុល្លារក្នុងឆ្នាំ២០០០ កើនដល់ ១.៦ពាន់លានដុល្លារក្នុងឆ្នាំ២០១៧។ដូចដែលបានលើកឡើងកម្ពុជាក៏ដូចជាប្រជាជនដែលរស់នៅក្នុងប្រទេសទាំងមូលដែលទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចតាមរយៈពាណិជ្ជកម្មសេរីរបស់អាស៊ាននេះដែរ។ ក្នុងឱកាសនេះប្រជាជនយើងក៏ទទួលបានផលប្រយោជន៍យ៉ាងច្រើនដែរដូចជា ៖

➢កសិកម្ម អត្ថប្រយោជន៍នេះបានទៅលើប្រជាពលរដ្ឋដែលជាកសិករមានឱកាសនាំចេញទំនិញកសិកម្មទៅក្រៅប្រទេសបានកាន់តែច្រើនដោយសារប្រទេសយើងដែលពឹងផ្អែកមួយចំណែកលើវិស័យកសិកម្មក្នុងការនាំចេញ។ ការធ្វើពាណិជ្ជកម្មសេរីនឹងផ្តល់នូវភាពងាយស្រួលនិងបរិមាណនាំចេញកាន់តែច្រើនតាមរយៈការលើកលែងពន្ធ។

➢ឱកាសការងារនិងមានកាន់តែច្រើនសម្រាប់ប្រជាជននៅពេលមានការវិនិយោគផ្ទាល់ពីបរទេសដូចជាការបង្កើតការរោងចក្រដែលផ្តល់ការងារដល់អ្នកក្រីក្រមួយភាគធំពិសេសរោងចក្រកាត់ដេរ និងវាយនភណ្ឌដែលជាវិស័យសំខាន់មួយសម្រាប់ប្រទេសកម្ពុជាក្នុងការនាំចេញទៅក្រៅប្រទេសបានជាក់ស្តែងទៅកាន់ប្រទេសដែលជាដៃគូពាណិជ្ជកម្មអាស៊ានដូចជា អូស្រ្តាលី ចិន កូរ៉េខាងត្បូងជាដើម។

[15] http://www.information.gov.kh/articles/43044

➢ចំណេះដឹងបច្ចេកវិទ្យាត្រូវបាននាំមកជាមួយនឹងលំហូរនៃអ្នកវិនិយោគបរទេស។ នៅពេលពួកគេមកវិនិយោគឬបើកក្រុមហ៊ុន និងរោងចក្រពួកគេនឹងនាំមកនូវបច្ចេកវិទ្យាទាំងនោះមកដំណើរការដែលអាចឱ្យប្រជាជនយើងឆ្លៀតឱកាសទទួលបានចំណេះដឹងជាពិសេសគឺឱកាសការងារ។

➢ក្រៅពីនេះប្រជាជនអាចទិញទំនិញដែលនាំចូលពីក្រៅប្រទេសដូចជា កូរ៉េ ជប៉ុន ចិន និងបណ្ដាប្រទេសសមាជិកអាស៊ានផ្សេងទៀតក្នុងតម្លៃធូរថ្លៃជាងមុនដោយសារពន្ធនឹងត្រូវបានកាត់បន្ថយដូចនេះទំនិញនឹងចុះតម្លៃតាមហ្នឹងដែរ[16] ។ អាចថានេះជាពេលវេលាដ៏ឧត្តុង្គឧត្តមបំផុតដែលកម្ពុជាមានកិត្តិយសបានទទួលធ្វើជាម្ចាស់ផ្ទះដែលរៀបចំកិច្ចប្រជុំកំពូលអាស៊ានក្នុងឆ្នាំ២០២២ និងកិច្ចប្រជុំពាក់ព័ន្ធដទៃទៀតដែលមានការចូលរួមពីថ្នាក់ដឹកនាំកំពូលៗនៅលើពិភពលោក។ចាប់ពីថ្ងៃទី១០-១៣ខែវិច្ឆិកាគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់កម្ពុជាក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាននេះ។ ក្នុងកិច្ចប្រជុំកំពូលអាស៊ាននេះកម្ពុជាបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន៤ សំដៅធ្វើឱ្យសេដ្ឋកិច្ច និងទំនាក់ទំនងអាស៊ានកាន់តែល្អប្រសើរ។ គោលដៅយុទ្ធសាស្ត្រទាំងនោះរួមមាន៖ ទី១ ការពង្រឹងការតភ្ជាប់ឌីជីថលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ទី២ ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ដើម្បីភាពប្រកួតប្រជែងរបស់អាស៊ាន ទី៣ ការជំរុញសមាហរណកម្មបរិយាប័ន្ន ភាពធន់ និងភាពប្រកួតប្រជែងអាស៊ានឱ្យខ្លាំងជាងមុន ទី៤ អាស៊ានជាសកលសម្រាប់ភាពរីកចម្រើន និងការអភិវឌ្ឍសំដៅជំរុញកំណើនសេដ្ឋកិច្ចឡើងវិញប្រកបដោយចីរភាព បរិយាប័ន្ននិងភាពធន់។ ម្យ៉ាងទៀត សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជាក៏បានលើកឡើងដោយកោតសរសើរផងដែរនូវសមិទ្ធផលសំខាន់មួយសម្រាប់អាស៊ានគឺកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ដែលជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការបើកទូលាយសេដ្ឋកិច្ចព្រមទាំងធ្វើពិពិធកម្មទីផ្សារតំបន់។ ក្រៅពីកិច្ចសហការដែលបានលេចឡើងជាផ្លែផ្កាសម្ដេចក៏មិនភ្លេចផងដែរនូវវត្តមានដ៏មានសារៈសំខាន់របស់វិស័យឯកជនក្នុងការចូលរួមស្ដារកំណើនសេដ្ឋកិច្ច និងដំណើរការសកម្មភាពសង្គមសេដ្ឋកិច្ចឡើងវិញក្នុងតំបន់នាពេលកន្លងមក។ សម្ដេចនាយករដ្ឋមន្ត្រីក៏បានគូសបញ្ជាក់ផងដែរអំពីលទ្ធផលជាក់ស្ដែងដែលបានមកពីការចូលរួមរបស់វិស័យឯកជនក្នុងនោះរួមមានការជំរុញសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានការលើកកម្ពស់នវានុវត្តន៍ការអភិវឌ្ឍធនធានមនុស្សការកាត់បន្ថយគម្លាតឌីជីថលជាដើម។ យោងតាមការវាយតម្លៃ និងព្យាករណ៍របស់ការិយាល័យស្រាវជ្រាវនូវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) សេដ្ឋកិច្ចអាស៊ានកំពុងងើបឡើងវិញជាមួយនឹងការសម្រេចបាននូវកំណើនផលិតផលក្នុងស្រុកសរុប (GDP) ក្នុងអត្រា ៣,១% ក្នុងឆ្នាំ ២០២១ ជាមួយនឹងការរំពឹងទុកនូវកំណើនក្នុងអត្រា ៥,៣% និង ៤.៩% ក្នុងឆ្នាំ ២០២២ និង ២០២៣ រៀងគ្នា។ គួរជម្រាបថានេះជាការដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រខាងលើគឺធ្វើឡើងក្នុងឱកាសពិធីបើកកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន ឆ្នាំ២០២២ នាព្រឹក ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២២[17]។ ក្រឡេកមកមើលជំនាញដែលមានទីផ្សារការងារច្រើនទាំងពេលបច្ចុប្បន្ននិងអនាគតដែលរួមមានជំនាញវិស្វកម្មអគ្គិសនី វិស្វកម្មមេកានិច បរិស្ថានវិទ្យា គីមីអាហារ សវនកម្ម ប្រព័ន្ធផ្សព្វផ្សាយ កសិកម្ម ស្ថាបត្យកម្ម និងសំណង់ស៊ីវិល គឺជាជំនាញដែលមានតម្រូវការទីផ្សារការងារច្រើនទាំងពេលបច្ចុប្បន្ននិងអនាគតលោក ។ នេះបើតាម លោក សូសុធីរ សាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រអប់រំរាជបណ្ឌិតសភាកម្ពុជា ។ អ្នក

[16] https://m.facebook.com/Cambofinance/photos/a.618697228625010/1083034305524631/?type=3

[17] https://economy.ams.com.kh/economic/news/cambodia-as-chair-of-asean-has-set-strategic-goals/

ស្រាវជ្រាវរូបនេះបានសង្កត់ធ្ងន់ ថាជំនាញគណនេយ្យ ធនាគារនិង ហិរញ្ញវត្ថុ នឹងលែងមានទីផ្សារការងារច្រើនព្រោះបច្ចេកវិទ្យានៅក្នុងវិស័យនេះគឺកំពុងតែជំនួសដោយមនុស្សជាបណ្តើរៗហើយ ។ លោក សូសុជីវ បណ្ឌិតវិទ្យាសាស្ត្រអប់រំនិងជាសាស្ត្រាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជាបានមានប្រសាសន៍ថា ការជ្រើសរើសជំនាញនៅសាកលវិទ្យាល័យជាការជ្រើសរើសមុខរបរសម្រាប់ថ្ងៃអនាគត ។ បើតាមអ្នកស្រាវជ្រាវរូបនេះការសិក្សានៅថ្នាក់ចំណេះដឹងទូទៅគ្រាន់តែជាការបុកគ្រឹះផ្ទះប៉ុណ្ណោះតែការរៀនជំនាញនៅ សាកលវិទ្យាល័យគឺជាការសាងសង់ផ្ទះឡើងទៅលើតាមម៉ូដរៀងៗខ្លួន។«ជំនាញ វិស្វកម្មអគ្គិសនី វិស្វកម្ម មេកានិច បរិស្ថានវិទ្យា គីមីអាហារ សវនកម្ម ប្រព័ន្ធផ្សព្វផ្សាយ សំណង់ស៊ីវិល ស្ថាបត្យកម្ម និងកសិកម្ម គឺជាជំនាញដែលមានទីផ្សារការងារច្រើនទាំងពេលបច្ចុប្បន្ននិង៥ឆ្នាំខាងមុខទៀត»។ នេះជាការអះអាងចំៗរបស់លោកសូសុជីវដោយដកស្រង់ចេញពីសៀវភៅមគ្គុទេសក៍សម្រាប់ការជ្រើសរើសគ្រឹះស្ថានសិក្សានិងមុខជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា។ បើតាមបណ្ឌិតផ្នែកវិទ្យាសាស្ត្រអប់រំរូបនេះនៅថ្ងៃខាងមុខជំនាញដែលធ្វើការនៅធនាគារនឹងលែងត្រូវប៉ាន់ទៀតហើយ។ លោកពន្យល់យ៉ាងដូច្នេះថា៖ « ធនាគារសព្វថ្ងៃគេមាន App និង ATM ដែលអាចដាក់និងដកលុយដោយមិនចាំបាច់ទៅធនាគារ។ បើមនុស្សយល់ដឹងលើវិស័យនេះកាន់តែច្រើនគេដកឬដាក់លុយដោយខ្លួនឯងបាន។ ដូច្នេះបុគ្គលិកធនាគារគេនឹងត្រូវការកាន់តែតិច» ។ លោកសូសុជីវបានជំរុញឱ្យនិស្សិតចាប់អារម្មណ៍រៀនជំនាញកសិកម្មព្រោះជំនាញនេះកំពុងមានតម្រូវការ ច្រើនតែមាននិស្សិតរៀនតិចស្របពេលដែលប្រជាជនកម្ពុជាភាគច្រើនតែនៅធ្វើស្រែតាមបែបបុរាណ ។ លោក បានពន្យល់យ៉ាងដូច្នេះថា«បើតាមទស្សនៈខ្មែរយើងពីដើមគេគិតថាខំរៀនអស់ប្រាក់ជាច្រើនមិនឱ្យកូនវិលទៅធ្វើស្រែវិញទេ ។ នេះជាទស្សនៈចាស់គំរិលព្រោះបច្ចុប្បន្នកសិកម្មឥឡូវមិនដូចពីមុនទេគេធ្វើស្រែឬក៏ចិញ្ចឹមសត្វគេមានបច្ចេកទេសត្រឹមត្រូវ » បើទោះបីជំនាញទាំង៩ខាងលើមាន ទីផ្សារការងារខ្ពស់មែនតែ សាស្ត្រាចារ្យរូបនេះបានណែនាំឱ្យនិស្សិតកុំភ្លេចរៀនផ្នែកវិទ្យាសាស្ត្រសង្គមនិងសិល្បៈផងដែរព្រោះវាជាមុខវិជ្ជាដ៏មានតម្លៃសម្រាប់ប្រទេសជាតិប៉ុន្តែមាននិស្សិតរៀនតែ៧ភាគប៉ុណ្ណោះ។ ក្រៅពីជ្រើសរើសជំនាញស្នូលហើយនោះលោកសូសុជីវចង់ឱ្យនិស្សិតខិតខំរៀនភាសាបរទេសនិងកុំព្យូទ័រដែលជាជំនាញដើម្បីមានសមត្ថភាពគ្រប់គ្រាន់ប្រឡូកក្នុងការងារនៅពេលបច្ចុប្បន្ននិងថ្ងៃអនាគត [18] ។

ទៀតសោតយើងក្រឡេកទៅមើលការឆ្លើយប្រាប់វិទ្យុមិត្តភាពកម្ពុជា-ចិន លោកគង់សេរីវ័ន្តប្រធានការិយាល័យព័ត៌មាននៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP)បានឱ្យដឹងថាក្នុងនាមប្រជាពលរដ្ឋម្នាក់លោកយល់ឃើញការងារទាំងអស់ពិតមានសារសំខាន់ព្រោះថាមនុស្សម្នាក់ៗមានការងារធ្វើទើបមានប្រាក់ចំណូល ៖ សំឡេង ៖ « ការងារអ្វីក៏មានសារសំខាន់ដែរ បើអ្នករាជការប្រកបវិជ្ជាជីវៈ របស់ខ្លួនទៅជាចំណែកប្រជាពលដ្ឋតាមមូលដ្ឋានគាត់ធ្វើតាមមុខជំនាញរបស់ខ្លួនបើមានអាជីវករធ្វើយ៉ាងមិចឱ្យការងារខ្លួនមានការរីកចម្រើនមានប្រយោជន៍ទៅកសិករជំនាញកសិកម្មគាត់ធ្វើកសិកម្មអ្នកខ្លះធ្វើសិប្បកម្មព្រោះថាយើងម្នាក់ៗត្រូវការចំណាយក្នុងជីវភាពរាល់ថ្ងៃ។ដូច្នេះត្រូវមានប្រាក់ចំណូលជាប្រចាំដើម្បីចំណាយលើម្ហូបអាហារព្យាបាលជំងឺផ្តល់ឱ្យកូនសិក្សាទាំងនេះសុទ្ធតែត្រូវការថវិកា » ។

[18] https://thmeythmey25.com/detail/83905

លោកជំទាវ ឆាយលីណាទីប្រឹក្សាក្រសួងព័ត៌មាន និងជាអនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជាបានប្រាប់វិទ្យុមិត្តភាពកម្ពុជាចិនដោយបង្ហាញទស្សនៈផ្ទាល់ខ្លួនថាបើសិនជាមនុស្សយើងនៅទំនេរច្រើនពេកធ្វើឱ្យមានកើតមានជំងឺផ្លូវចិត្តធុញថប់ផ្លូវអារម្មណ៍ប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយផងដែរ។ «កាលណាអត់ការងារធ្វើមានផលលំបាកចំនួន៣តាមការមើលឃើញទូទៅរបស់ខ្ញុំ»។ ទីមួយធ្វើឱ្យយើងស្រ្តេសគិតអ្វីមិនសូវយល់ទេកាលណាយើងទំនេរពេក ទីពីរធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចយើងធ្វើថាក្នុងការរស់នៅយើងត្រូវការចរន្តចាយវាយចុះឡើង ហើយបើយើងអត់ការងារធ្វើយើងក៏អត់ប្រាក់កម្រៃដែរ និងចំណុចទីបីបើយើងអត់ការងារធ្វើគឺមានន័យថាយើងអត់បានចូលរួមការងារសកម្មភាពសង្គមទេហើយធ្វើឱ្យប៉ះពាល់សេដ្ឋកិច្ចជាតិដោយបាត់បង់កម្លាំងពលកម្មបើយើងជាយុវជនមានកម្លាំងពេញលេញ។ កាលណាយើងជួយរកប្រាក់ចំណូលជួយគ្រួសារយើងផ្លូវចិត្តយើងបានល្អដោយសារសេដ្ឋកិច្ចយើងមានចរន្តចេញចូល។ យើងអាចមានលទ្ធភាពជួយសហគមន៍តាមលទ្ធភាព។ សកម្មភាពយើងតូចៗនេះឯងដែលធ្វើឱ្យសង្គមជាតិរីកចម្រើននេះជាការយល់ឃើញរបស់ខ្ញុំ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញរួចហើយនូវទិសដៅការងារមួយចំនួននោះរួមមាន ៖ ដោយបន្តខិតខំលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើងពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីការងារបន្តពង្រឹងយន្តការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព។ ពង្រឹងនូវភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកាតព្វកិច្ច និងការទទួលខុសត្រូវស្របច្បាប់របស់កម្មករនិយោជិត និងនិយោជក។ បន្តប្រែក្លាយរោងចក្រ សហគ្រាស មួយជាសហគមន៍សុខសាន្តមួយរបស់កម្មករនិយោជិតដែលពោរពេញដោយសមត្ថភាពលក្ខខណ្ឌការងារល្អប្រសើរផលិតភាពឥរិយាបថការងារ ការទទួលខុសត្រូវសង្គម និងមានសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ។ បើយោងតាមសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣៦នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២២បានឱ្យដឹងថារាជរដ្ឋាភិបាលបានបន្តលើកកម្ពស់ការការពារសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈថែរក្សាសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈផ្តល់អត្ថប្រយោជន៍នានាជូនបងប្អូនកម្មករនិយោជិតរួមទាំងការផ្តល់កិច្ចគាំពារសង្គមផងដែរស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលច្បាប់ស្តីពីការងារច្បាប់ស្តីពីសហជីព និងអនុសញ្ញាអន្តរជាតិខាងការងារទាំង១៣ ដែលកម្ពុជាបានផ្តល់សច្ចាប័នតាមរយៈយន្តការត្រីភាគីសម្រាប់សំវាទសង្គមជាអាទិ៍ក្រុមប្រឹក្សាអាជ្ញាកណ្តាលគណៈកម្មការប្រឹក្សាការងារក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមារួមទាំងយន្តការត្រីភាគីបូកជាច្រើនទៀត។ កន្លងមកនេះដែររាជរដ្ឋាភិបាលនឹងអភិវឌ្ឍវិស័យកាត់ដេរផលិតស្បែកជើង និងកាបូបផ្សេងៗនៅកម្ពុជាឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថានមានភាពធន់មានតម្លៃបន្ថែមខ្ពស់ផ្តោតលើផលិតផលថ្លៃខ្ពស់ និងមានលក្ខណៈពិសេសមានភាពប្រកួតប្រជែងខ្ពស់និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ចមុនដំណាច់ឆ្នាំ២០២៧ ។ នៅប្រទេសកម្ពុជាផ្តើមចេញពីសន្តិភាពពេញលេញ និងការអភិវឌ្ឍទៅលើគ្រប់វិស័យបានបង្កលក្ខណៈកាន់តែងាយស្រួលដល់ប្រជាពលរដ្ឋគ្រប់រូបមានឱកាសប្រកបការងារតាមវិជ្ជាជីវៈចំណេះជំនាញ និងតាមលទ្ធភាពរៀងៗខ្លួនដើម្បីទទួលបានកម្រៃសមរម្យក្នុងការលើកតម្កើងកម្ពស់សេដ្ឋកិច្ចគ្រួសារ។ ក្រៅពីការងារក្នុងប្រទេសរាប់លានកន្លែង គឺប្រជាពលរដ្ឋកម្ពុជាក៏បានទៅធ្វើការងារនៅបរទេសជាច្រើនសែននាក់ទៀតផងដែរដែលជំរុញឱ្យពួកគេមានចំណូលកាន់តែច្រើនឡើង។ ជាមួយគ្នានេះ

រាជរដ្ឋាភិបាលបានខិតខំស្វែងរកដៃគូវិនិយោគស្វែងរកទីផ្សារកសិផលជូនប្រជាពលរដ្ឋ និងបានបង្កើតការងារកាន់តែច្រើនដល់ភូមិស្រុកប្រជាពលរដ្ឋ៖ ដូចជា បង្កើតរោងចក្រសហគ្រាសកសិដ្ឋាននិងអភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ជាដើម។ របាយការណ៍នេះបានបង្កើតការងារឱ្យទៅដល់កូនចៅអ្នកស្រុកបានកាន់តែច្រើនថែមទៀតធ្វើឱ្យពួកគាត់អាចកាត់បន្ថយការចំណាយ និងកាត់បន្ថយចំណាកស្រុកជាដើម។ ត្រង់ចំណុចនេះសមដូចសុភាពសិតខ្មែរ យើងមួយបានលើកឡើងថា « ការងារជាមាសប្រាក់ » ។ និយាយរួមទៅបើមើលតាមសន្ទុះ និងការខិតខំប្រឹងប្រែងរបស់ប្រជាពលដ្ឋគ្រប់រូបក្នុងការស្វះស្វែងរកធ្វើការងារមិនថាការងារខ្លួនឯង ឬស៊ីឈ្នួលឱ្យគេឡើយ គឺសុទ្ធតែបាននាំមកនូវប្រាក់ចំណូលដូចគ្នាសម្រាប់លើកកម្ពស់ជីវភាពគ្រួសារកាន់តែល្អប្រសើរ។ បើជីវភាពប្រជាពលរដ្ឋធូធារហើយនោះសង្គមកម្ពុជាទាំងមូលពិតជាមានការអភិវឌ្ឍគ្រួសារនីមួយៗរស់នៅប្រកបដោយក្តីសប្បាយរីករាយ។ ចំណែកសេដ្ឋកិច្ចជាតិវិញក៏រីកចម្រើនផងដែរតាមនេះដែរខណៈប្រជាពលរដ្ឋគ្រប់រូបជាកម្លាំងចលករដ៏សំខាន់ក្នុងការជួយទ្រទ្រង់សេដ្ឋកិច្ចជាតិព្រោះថាបើសិនជាប្រជាជនមិនមានការងារធ្វើទេបន្ទុកកាន់តែច្រើននោះធ្លាក់មកលើរាជរដ្ឋាភិបាលក្នុងការដោះស្រាយ[19]។

**២.៣.៤ ទ្រឹស្តីនៃការងារ**

លោក **Philosophy** បានឱ្យទ្រឹស្តីទាក់ទងនឹងការងារថា ៖ នរណាមានការងារល្អជាវេជ្ជបណ្ឌិត ជាវិស្វករជាថៅកែ ជាមន្ត្រីរដ្ឋការខ្ពស់ ជាទីប្រឹក្សានាយករដ្ឋមន្ត្រី ជារដ្ឋមន្ត្រី ជានាយករដ្ឋមន្ត្រី តែងទទួលបាននូវកិត្តិយសខ្ពង់ខ្ពស់ដែលមនុស្សទូទៅទទួលស្គាល់ ហើយតែងប្រកួតប្រជែងចង់បានពីព្រោះការងារថ្នាក់ខ្ពស់ទាំងនោះ ធ្វើឱ្យមនុស្សបានទទួលប្រាក់ខែខ្ពស់ ដូច្នេះធ្វើឱ្យជីវភាពធូធារ និងមានមុខមាត់។ ប៉ុន្តែការងារថ្នាក់ខ្ពស់មានកិត្តិយសខ្ពស់មួយចំនួនរកប្រាក់បានមកដោយអំពើមិនសុចរិត គឺដោយអំពើពុករលួយ អំពើលួចជាតិ ដែលនេះបង្ហាញឱ្យឃើញថាការងារមិនមែនជាផ្លាកសំគាល់កិត្តិយសនោះទេផ្ទុយទៅវិញចរិកមនុស្សទេដែលអាចថោកទាប[20] ។

អនុបណ្ឌិត **ហេង សុភា-ម៉ៃ រ៉ាម** បានឱ្យទ្រឹស្តីទៅលើការងារ គឺជាបញ្ហាមួយដែលមានសារៈសំខាន់បំផុតក្នុងចំណោមបញ្ហាសង្គមនានាទៀត។ សង្គមវិទូជាច្រើនបានបញ្ជាក់ពីអត្ថន័យរបស់ពាក្យថា ការងារដោយពួកគាត់បានពន្យល់ថា ការងារគឺសំដៅយកទាំងការងារគ្មានប្រាក់បៀវត្ស និងមានប្រាក់បៀវត្ស។ ដូច្នេះហើយយោងតាមទ្រឹស្តីខាងលើនេះយើងអាចនិយាយបានថា ការងារគឺជាទង្វើទាំងឡាយណាដែលសម្តែងចេញតាមរយៈសកម្មភាពរបស់មនុស្ស[21] ។

[19] https://dap-news.com/national/2022/05/04/242262/

[20]https://sambatt.wordpress.com/2011/09/04/%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%84%E1%9E%B6%E1%9E%9A/

[21] https://www.facebook.com/share/gGKnFLMd921nBn7Y/?mibextid=WC7FNe

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃទីផ្សារការងារ

ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០២៧ ស្ថានភាពទីផ្សារនិងបរិយាកាសការងារនៅលើពិភពលោកនឹងប្រែប្រួលគួរឱ្យកត់សំគាល់។ ការស្ទង់មតិមួយ ដែលគេបានធ្វើជាមួយបណ្តានិយោជក និងបានចេញផ្សាយនៅថ្ងៃចន្ទ ខែឧសភាឆ្នាំនេះបង្ហាញឱ្យឃើញដូច្នេះ។ វេទិកាសេដ្ឋកិច្ចពិភពលោក ដែលគេបានស្គាល់តាមរយៈការរៀបចំវេទិកាសេដ្ឋកិច្ចប្រចាំឆ្នាំនៅទីក្រុងដាវ៉ូសប្រទេសស្វីសជាអ្នកបញ្ចេញលទ្ធផលនៃការស្ទង់មតិនោះ។ នេះបើយោងតាមសារព័ត៌មានអ៊ិនខ្វៃអ៊ើរើ( Inquirer )។ លទ្ធផលនៃការស្ទង់មតិមួយដែលបានចេញផ្សាយដោយវេទិកាសេដ្ឋកិច្ចពិភពលោកបានឱ្យដឹងថាប្រហែល១ភាគ៤ នៃការងារត្រូវបានកំណត់ថានឹងផ្លាស់ប្តូរក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ របាយការណ៍ចង្អុលប្រាប់ថាការងារថ្មីប្រហែល ៦៩ លាននឹងត្រូវបានបង្កើតឡើងប៉ុន្តែការងារ ៨៣ លានកន្លែង នឹងត្រូវបាត់បង់នៅត្រឹមឆ្នាំ ២០២៧ ជាហេតុបណ្តាលឱ្យការងារបច្ចុប្បន្នថយចុះក្នុងអត្រា២ភាគរយ។លទ្ធផលនៃការស្ទង់មតិនេះគឺផ្អែកលើជាតុចូលដែលវេទិកាសេដ្ឋកិច្ចពិភពលោកបានទទួលពីវិស័យឯកជនចំនួន៨០០ក្រុមហ៊ុនដែលបាននិងកំពុងផ្តល់ការងារឱ្យមនុស្សជាង១១លាននាក់។ លទ្ធផលខាងលើក៏ផ្អែកលើការប្រើប្រាស់សំណុំទិន្នន័យការងារសរុបចំនួន ៦៧៣លានកន្លែងដែរ។ សេចក្តីសង្ខេបនៃរបាយការណ៍បានបញ្ជាក់ថា វិស័យបច្ចេកវិទ្យា និងឌីជីថលភាវូបនីយកម្មជាកត្តាជំរុញនៃការបង្កើតការងារ និងជាកត្តាបំផ្លាញការងារដែរ។ របាយការណ៍នេះបានសង្កត់ធ្ងន់ថា ៖ « ការទទួលយកបច្ចេកវិទ្យារួមផ្សំនិងការបង្កើនការធ្វើឌីជីថលភាវូបនីយកម្មនឹងបង្កឱ្យមានការរង្គោះរង្គើទីផ្សារការងារគួរឱ្យកត់សម្គាល់នាពេលអនាគត»។ ប្រភពដដែលបានអះអាងថាមុខងារដែលនឹងថយចុះលឿនបំផុតគឺផ្នែកលេខាធិការនិងផ្នែករដ្ឋបាលដូចជាបេឡាករនិងអ្នកគិតលុយនៅតាមធនាគារជាដើម គឺសុទ្ធតែមានហានិភ័យដោយសារតែការងារទាំងនោះអាចបំពេញដោយប្រព័ន្ធស្វ័យកម្មនៅពេលដែលតម្រូវការអ្នកជំនាញវិស្វកម្មតាមប្រព័ន្ធបញ្ញាសិប្បនិម្មិត ( AI ) និងអ្នកជំនាញផ្នែកសន្តិសុខតាមអ៊ីនធឺណិតត្រូវបានគេរំពឹងថានឹងកើនឡើងយ៉ាងខ្លាំង ។

### ៣.១.១ គោលនយោបាយ

គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ នាព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១នេះបានបើកកិច្ចប្រជុំលើកទី៥របស់ខ្លួនក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥។ កិច្ចប្រជុំនេះមានការចូលរួមពីសំណាក់តំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធអភិបាល និងអភិបាលរងរាជធានី-ខេត្តដែលជាសមាជិក សមាជិកានៃគណៈកម្មការអន្តរក្រសួងព្រមទាំងតំណាងអង្គការអន្តរជាតិខាងការងារ (ILO)។ កិច្ចប្រជុំនេះមានគោលបំណងពិនិត្យ និងវាយតម្លៃពីវឌ្ឍនៈភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរការងារឆ្នាំ២០១៥-២០២៥ និងបញ្ហាប្រឈមនៅក្នុងបរិបទជំងឺកូវីដ-១៩។ ឯកឧត្តមបណ្ឌិតអ៊ិត សំហេង បានស្នើរសុំថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ រដ្ឋបាលរាជធានី-ខេត្ត វិស័យឯកជនបង្កើនការ

យកចិត្តទុកដាក់បន្ថែមទៀតក្នុងការចូលរួមអនុវត្តគោលនយោបាយនេះដើម្បីធ្វើការផ្លាស់ប្តូរ និងលើកស្ទួយរចនាសម្ព័ន្ធឧស្សាហកម្ម ពីឧស្សាហកម្មអតិពលកម្មទៅជាឧស្សាហកម្មពលកម្មផ្អែកលើជំនាញនៅឆ្នាំ២០២៥ ក៏ដូចជាការលើកកម្ពស់ការប្រកួតប្រជែង និងផលិតភាពសំដៅប្រែក្លាយពីឧស្សាហកម្មមានតម្លៃបន្ថែមទាបទៅជាឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ស្របតាមគោលនយោបាយជាតិអភិវឌ្ឍវិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានកំណើនខ្ពស់ប្រកបដោយចីរភាពនិងបរិយាប័ន្ន សម្រាប់ភាពសុខដុមក្នុងសង្គមដោយនឹងផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសការងារដ៏សមរម្យនិងប្រកបដោយផលិតភាពការងារខ្ពស់ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង ក៏បានបញ្ជាក់បន្ថែមថាក្នុងការអនុវត្តគោលនយោបាយជាតិនេះក្រសួងស្ថាប័នជាច្រើនទាំងថ្នាក់ជាតិ រួមទាំងថ្នាក់ក្រោមជាតិត្រូវចូលរួមអនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រាន់តែមាន តួនាទីជាលេខាធិការដ្ឋានសម្រាប់សម្របសម្រួលការអនុវត្តនេះតែប៉ុណ្ណោះ។ នេះមានន័យថាការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធពិតជាមានភាពចាំបាច់ណាស់ដើម្បីជំរុញឱ្យការអនុវត្តគោលនយោបាយនេះកាន់តែមានប្រសិទ្ធភាពនិងលទ្ធផលកាន់តែប្រសើរ។ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានថ្លែងអំណរគុណចំពោះអង្គការអន្តរជាតិខាងការងារ (ILO) ដែលតែងតែបានផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធក្នុងការផ្តល់ជំនួយថវិកាព្រមទាំងបច្ចេកទេសមកលេខាធិការដ្ឋា គ.អ.ម.ក នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយនេះ។ អង្គការអន្តរជាតិខាងការងារ (ILO) គឺជាដៃគូយ៉ាងសំខាន់ដែលមិនអាចខ្វះបាននៅក្នុងការអភិវឌ្ឍវិស័យការងារនៅកម្ពុជា។ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ មិនត្រឹមតែមានគោលបំណងជួយលើកតម្កើងជីវភាព ភាពថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ភាពសុខដុមរមនាសង្គម តាមរយៈការបង្កើតឱកាសការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ការអភិវឌ្ឍជំនាញនិងធនធានមនុស្សនៅក្នុងប្រទេសប៉ុណ្ណោះ ទេប៉ុន្តែគោលនយោបាយនេះក៏មានវិធានការការពារនិងលើកកម្ពស់សិទ្ធិនិងអត្ថប្រយោជន៍ពលករកម្ពុជាដែលកំពុងធ្វើការនៅក្រៅធ្វើប្រទេសផងដែរ ។

### ៣.១.២ បេសកកម្ម និងចក្ខុវិស័យ

ក.បេសកកម្ម

ប្រទេសកម្ពុជាដើម្បីឈានទៅដល់ការសម្រេចបាននូវចក្ខុវិស័យដូចខាងក្រោមក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានបេសកកម្មចម្បងៗ ដូចជា៖

- ពង្រឹងនិងជំរុញការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដើម្បីធានាបាននូវលក្ខខណ្ឌការងារល្អប្រសើរ និងរក្សាបាននូវភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ។
- ពង្រឹងសុខភាពនិងសុវត្ថិភាពការងារនៅនិងកន្លែងធ្វើការ ការពារទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។
- ពង្រឹងការអភិវឌ្ឍនិងការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា ស្តង់ដារជាតិ សមត្ថភាពកម្មវិធី និងឯកសារសិក្សាដោយផ្អែកលើសមត្ថភាព ព្រមទាំងឯកសារធ្វើតេស្តបញ្ជាក់សមត្ថភាពឱ្យទូទាំងព្រះរាជាណាចក្រកម្ពុជាដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យមានប្រសិទ្ធភាពខ្ពស់ និងមានការទទួលស្គាល់ជាសាធារណៈកម្រិតជាតិ និងអន្តរជាតិ។

- ប្រែក្លាយការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ឱ្យស្របទៅតាមការវិវត្តនៃតម្រូវការក្នុងវិស័យឧស្សាហកម្ម និងសហគមន៍។
- ពង្រឹងការអនុវត្តគោលការណ៍បណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយសមធម៌ដោយយកចិត្តទុកដាក់ជាពិសេសដល់ស្ត្រីភេទ ជនពិការ ជនបាត់បង់ឱកាស ជនមានឱកាសតិចតួចក្នុងសង្គម យុវជនទីទ័លក្រ និងសិស្សដែលបានបោះបង់ការសិក្សា។
- ផ្តល់សេវាការងារជាមូលដ្ឋានប្រកបដោយប្រសិទ្ធភាពដូចជាការផ្គូរផ្គងគ្នារវាងអ្នកស្វែងរកការងារធ្វើ និងកន្លែងការងារទំនេរដើម្បីបង្កើនប្រសិទ្ធភាពទីផ្សារការងារ។ប្រមូលវិភាគនិងចងក្រងព័ត៌មានទីផ្សារការងារដើម្បីជាមូលដ្ឋានគ្រឹះក្នុងការផ្តល់សេវាការងារប្រកបដោយប្រសិទ្ធភាព ព្រមទាំងផ្តល់ជាប្រភពទិន្នន័យដល់អ្នករៀបចំគោលនយោបាយអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និយោជក និងសាធារណជនទូទៅ។
- អភិវឌ្ឍន៍គោលនយោបាយ និងបទបញ្ញានានា ដើម្បីរួមចំណែកបង្កើនឱកាសទទួលបានការងារ និងបង្កើតការងារទាំងក្នុងប្រទេស និងក្រៅប្រទេសជូនប្រជាពលរដ្ឋកម្ពុជា។ ផ្តល់សេវាផ្នែកសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាពតម្លាភាពគណនេយ្យភាព និងទាន់ពេលវេលាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារក្នុងគោលដៅជួយសម្រាលការលំបាកនានា នៅពេលជរាភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។
- ពង្រឹងសមត្ថភាពស្ថាប័ន បង្កើនប្រសិទ្ធភាពការងារ និងផ្តល់សេវាជូនប្រជាពលរដ្ឋ។ ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជន (Public-Private Partnership) ដើម្បីធានាបាននូវការផ្គត់ផ្គង់ធនធានហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍវិស័យការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ។
- ពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ។ លើកកម្ពស់សមធម៌យេនឌ័រនិងកាត់បន្ថយគម្លាតយេនឌ័រ ក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ខ.ចក្ខុវិស័យ**

ចក្ខុវិស័យរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺធានានិងលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ បង្កើតបរិយាកាសការងារ និងបង្កើនឱកាសការងារ និងធានាការគាំពារសង្គម ព្រមទាំងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យស្របទៅតាមតម្រូវការទីផ្សារការងារ ដើម្បីឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ សំដៅកាត់បន្ថយភាពក្រីក្រជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការបែងចែកផលនៃកំណើនប្រកបដោយសមធម៌ ស្របតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា និងទស្សនទានកម្ពុជាឆ្នាំ២០៣០ ។

## ៣.២ វិស័យដែលមានតម្រូវការទីផ្សារការងារសំខាន់ៗនៅកម្ពុជា

សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ខណៈដែលឆ្នាំ ២០២២នេះ សេដ្ឋកិច្ចមានកំណើនក្នុងអត្រាប្រមាណ ៥,៤% នេះបើតាមសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០២៣។ ជាក់ស្តែងប្រទេសកម្ពុជានាពេលបច្ចុប្បន្នបានពឹងផ្អែកទៅលើវិស័យសំខាន់ៗដូចជា វិស័យឧស្សាហកម្ម វិស័យកសិកម្ម វិស័យសុខាភិបាល វិស័យអប់រំនិងបណ្តុះបណ្តាល ព្រមទាំងធាតុផ្សំសំខាន់ៗផ្សេងទៀតដែលធ្វើឱ្យកម្ពុជារឹងមាំ ។

វិស័យឧស្សាហកម្មនឹងដើរតួនាទីសំខាន់សារជាថ្មីក្នុងយុទ្ធសាស្ត្រកំណើន ជាកម្លាំងចលករក្នុងការទ្រទ្រង់កំណើនរយៈពេលមធ្យមទៅវែង ជាវិស័យសក្តានុពលសម្រាប់បង្កើតការងារពិសេសសម្រាប់យុវជន និងជាជន្ទល់កំណើនសេដ្ឋកិច្ចថ្មីដែលនឹងស្រូបការវិនិយោគបន្ថែម ក្រៅពីវិស័យកសិកម្មនិងទេសចរណ៍។ ដើម្បីអនុវត្ត «គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឱ្យទទួលបានជោគជ័យរាជរដ្ឋាភិបាលនឹងខិតខំទ្វេដងក្នុងការអភិវឌ្ឍ ធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ការអភិវឌ្ឍ ការផ្ទេរ ការប្រើប្រាស់បច្ចេកវិទ្យា ក៏ដូចជាការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចចំណេះដឹងនិងការកែទម្រង់រចនាសម្ព័ន្ធស្ថាប័នចាំបាច់ ។ ជាក់ស្តែងការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ប្រឈមនឹងបញ្ហាគន្លឹះៗចំនួនប្រាំគឺទី១ កង្វះភាពជាអ្នកដឹកនាំ ការសម្របសម្រួល និងការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់កម្រិតពិសេសការគាំទ្រសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាផ្គត់ផ្គង់អគ្គិសនី ហេដ្ឋារចនាសម្ព័ន្ធនិងឡូជីស្ទីក ធនធានមនុស្ស និងជំនាញ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងទៀត ទី២ ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេសនិងជំនាញដែលជាអាទិភាពសំខាន់ ដើម្បីប្រែក្លាយកម្លាំងពលកម្មឱ្យមានជំនាញនិងមានសមត្ថភាពឈោងចាប់យកបច្ចេកទេសនិងបច្ចេកវិទ្យាខ្ពស់ ទី៣ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅមិនទាន់គ្រប់គ្រាន់ ពិសេសកង្វះការសម្របសម្រួលក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត បណ្តាញផ្លូវគមនាគមន៍ លូបញ្ចេញកាកសំណល់ និងការផ្តល់សេវាសាធារណៈឱ្យបានគ្រប់គ្រាន់ ទី៤ ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅមានកម្រិត ដែលជាឧបសគ្គដល់ការផ្តល់ហិរញ្ញប្បទានគម្រោងឧស្សាហកម្ម ទាំងយន្តការហិរញ្ញប្បទានសាធារណៈនិងឯកជន និងទី៥ បញ្ហាទីផ្សារការងារនិងទំនាក់ទំនងវិជ្ជាជីវៈ ដែលជាគន្លឹះធានាស្ថិរភាពទីផ្សារការងារនិងការផ្គត់ផ្គង់កម្លាំងពលកម្ម ក៏ដូចជាការលើកកម្ពស់ផលិតភាពនិងជីវភាពរបស់ពលករ។ ដោយឡែកវិស័យកសិកម្មត្រូវបានរំពឹងថានៅតែបន្តនិន្នាការកើនឡើងក្នុងអត្រា១,១%ក្នុងឆ្នាំ ២០២៣ ធៀបនឹងឆ្នាំ២០២២ដែលមាន០,៧%ដោយសារការរំពឹងទុកលើការបន្តរក្សាកំណើនល្អប្រសើរនៃអនុវិស័យដំណាំ និងចិញ្ចឹមសត្វស្របពេលដែលអនុវិស័យនេសាទត្រូវបានរំពឹងថានឹងងើបឡើងវិញ។ រីឯវិស័យសុខាភិបាលវិញរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញអំពីក្តីបំណងក្នុងការនាំយកប្រទេសកម្ពុជាឱ្យឆ្លងផុតពីភាពក្រីក្រផ្លាស់ប្តូរមុខមាត់ថ្មីដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ ហើយប្រែក្លាយជាប្រទេសអភិវឌ្ឍន៍ដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ នេះបើយោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងដំណាក់កាលទី៤ ដែលទើបបានដាក់ចេញជាសាធារណៈក្នុងពេលកន្លងមកនេះ។ ក្រសួងពាក់ព័ន្ធនានាក្នុងប្រទេសកម្ពុជា បានដាក់ចេញគោលនយោបាយរបស់ខ្លួនផ្សេងៗគ្នាដោយបង្ហាញពីយុទ្ធសាស្ត្រក៏ដូចជាទស្សនវិស័យរបស់ស្ថាប័នខ្លួនធ្វើយ៉ាងណាជម្រុញនិងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រគោល និងកម្មវិធីនយោបាយជាតិ។ ការកសាងធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ

គឺជាយន្តការសំខាន់ចម្បងទី១ ក្នុងយុទ្ធសាស្ត្រចតុកោណទាំង២ដំណាក់កាលចុងក្រោយ( ទី៣ និងទី៤ )ផងដែរ។ ចំពោះវិស័យអប់រំវិញ ត្រូវបានចាត់ទុកថា ជាវិស័យដ៏ចម្បងមួយដែលអាចជួយត្រួសត្រាយផ្លូវសម្រាប់កម្ពុជា ដើម្បីឆ្ពោះទៅកាន់គោលដៅឆ្នាំ២០៣០ របស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមកំណែទម្រង់វិស័យអប់រំ តាំងពីឆ្នាំ២០១៤ ដោយបានដាក់ចេញនូវ ផែនការយុទ្ធសាស្ត្រ ២០១៤-២០១៨ ទាក់ទងនឹងចក្ខុវិស័យ ២០៣០ របស់រដ្ឋាភិបាល គឺធ្វើយ៉ាងណា "កសាងសេដ្ឋកិច្ចឱ្យមានការប្រកួតប្រជែង សុខដុមនីយកម្ម និងនិរន្តរភាព"។ ផែនការយុទ្ធសាស្ត្រនេះ បានបង្ហាញផងដែរពីចក្ខុវិស័យរបស់ក្រសួងអប់រំ ដោយផ្តោតទៅលើ " ទិសដៅវិស័យអប់រំធ្វើយ៉ាងណា កសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរ បំផុតលើគ្រប់ផ្នែក ដើម្បីកសាងកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះដឹងធ្វើជាមូលដ្ឋាន "។ ក្រសួងអប់រំ បានបង្ហាញអំពីគោលនយោបាយអប់រំសំខាន់ចំនួន៣ដើម្បីជាពុម្ពគំរូមួយអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជាឆ្លើយតបទៅនឹងគោលដៅ អភិវឌ្ឍន៍ឆ្នាំ២០៣០។ ក្រឡេកទៅមើលវិស័យសុខភាពវិញ សុខភាពមានសារៈសំខាន់សម្រាប់បុគ្គលម្នាក់ៗហើយវារឹតតែចាំបាច់សម្រាប់ការរីកចម្រើនរបស់សង្គមជាតិមួយ។ វិស័យផលិតកម្មដែលជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចដ៏ចម្បងមួយនៅក្នុងប្រទេសទាមទារនូវកម្លាំងពលកម្មដ៏សកម្ម ឈ្លាសវៃ និងប្រកបដោយសុខភាពល្អមាំមួន។ បើសិនជាសុខភាពរបស់ពលរដ្ឋភាគច្រើនក្នុងប្រទេសមួយរងការយាយីពីជំងឺនិងរោគផ្សេងៗនោះការដើរទៅមុខ និងការរីកចម្រើនក៏មិនអាចទៅរួចនោះទេ។ ហើយវិស័យស្នូលដ៏សំខាន់មួយដែលជួយទ្រទ្រង់សុខមាលភាពរបស់ពលរដ្ឋនោះគឺវិស័យសុខាភិបាលដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវកម្លាំងពលកម្មដ៏រឹងមាំមួយក្នុងប្រទេស ។ យោងទៅតាមតាមសៀវភៅកម្ពុជាសម័យតេជោដើម្បីលើកកម្ពស់សុខភាព និងកាត់បន្ថយហានិភ័យឬគ្រោះថ្នាក់ដល់សុខុមាលភាពប្រជាពលរដ្ឋជាយថាហេតុ ក្រសួងសុខាភិបាលក៏បានធ្វើយុទ្ធនាការលុបបំបាត់គ្រូពេទ្យដែលបានចាក់ថ្នាំឱ្យប្រជាពលរដ្ឋនៅតាមភូមិដោយគ្មានច្បាប់អនុញ្ញាត។ យោងតាមរបាយការណ៍ថ្មីនៃក្រសួងសុខាភិបាលឆ្នាំ២០២០ទិសដៅ២០២១ បានឱ្យដឹងថាគិតត្រឹមខែធ្នូ ឆ្នាំ២០២០ កម្ពុជាមានមូលដ្ឋានសុខាភិបាលសាធារណៈគឺមណ្ឌលសុខភាពទូទាំងប្រទេសចំនួន១២៥០កន្លែង ខណៈឆ្នាំ ២០១៩ មាន១២២២ កន្លែងប៉ុស្តិ៍សុខភាពមានចំនួន១២៩កន្លែង ខណៈឆ្នាំ២០១៩ មាន១២៧កន្លែង និងមន្ទីរពេទ្យបង្អែកចំនួន១២៨ស្របពេល២០១៩មាន១២៦ មន្ទីរពេទ្យ ។ សម្រាប់វិស័យឯកជនគិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០ មានចំនួន១៤ ៤៣២កន្លែងខណៈឆ្នាំ២០១៩មាន១២ ៧៨៥កន្លែង ក្នុងនោះសម្រាប់រាជធានីភ្នំពេញគិតត្រឹមខែធ្នូឆ្នាំ ២០២២ មានមន្ទីរពេទ្យរដ្ឋចំនួន៩ទីតាំងមានមន្ទីរពេទ្យបង្អែកចំនួន៨ មណ្ឌលសុខភាព ចំនួន៤៣ ប៉ុស្តិ៍សុខភាពចំនួន៣៨ និងមានមន្ទីរពេទ្យឯកជន មន្ទីរពហុព្យាបាល ចំនួន ៧៤ មន្ទីរសម្រាកព្យាបាល ចំនួន ៣២៩ និងបន្ទប់សង្គ្រោះជំងឺចំនួនជាង១០០០ទីតាំង។

**៣.២.១ វិស័យសំខាន់ៗនាពេលបច្ចុប្បន្ននៅកម្ពុជា**

យោងទៅតាមការលើកឡើងរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈការងារនៅក្នុងវិស័យសំខាន់ៗជាងគេមានចំនួន៤ នៃសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្នមានដូចតទៅ៖

១.វិស័យសុខាភិបាល

រដ្ឋមន្ត្រីក្រសួងសុខាភិបាល **ម៉ម ប៊ុនហេង** បានការវាយតម្លៃលទ្ធផលការងារនៃវិស័យសុខាភិបាល នៅក្នុងឆ្នាំ២០២២ បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់និងបញ្ហាប្រឈមផង ជាពិសេសនៅក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ-១៩ការផ្តល់សេវានៃកម្មវិធីសុខភាពបន្តពូជសុខភាពមាតា ទារក កុមារនិងអាហារូបត្ថម្ភកម្មវិធីប្រយុទ្ធទៅនឹងជំងឺឆ្លងជំងឺមិនឆ្លងពុំរ៉ៃហើយនិងបញ្ហាសុខភាពសាធារណៈមួយចំនួនផ្សេងទៀត។ ជាមួយគ្នានេះវឌ្ឍនភាពដែលវិស័យសុខាភិបាលសម្រេចបាននៅឆ្នាំ២០២១ អាស្រ័យលើកត្តាជាសារវន្តមានដូចជា សន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម បង្កើនការវិនិយោគធនធាន រក្សានិរន្តរភាពនៃការផ្តល់សេវានិងការកែលម្អគុណភាព។ លោករដ្ឋមន្ត្រី ម៉ម ប៊ុនហេង មានប្រសាសន៍បែបនេះក្នុងកិច្ចប្រជុំពិនិត្យនិងវាយតម្លៃសមិទ្ធផលវិស័យសុខាភិបាលឆ្នាំ២០២១ និងទិសដៅបន្ត២០២២នៅទីស្តីការក្រសួងសុខាភិបាល នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២២។ លោករដ្ឋមន្ត្រីថ្លែងថា វិស័យសុខាភិបាល គឺជាវិស័យអាទិភាពមួយដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាតាមរយៈការលើកកម្ពស់ស្ថានភាពសុខភាពរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យកាន់តែល្អប្រសើរឡើងដែលផ្តល់ឱកាសដល់ប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គមសេដ្ឋកិច្ចដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យកាន់តែល្អប្រសើរ។ លោករដ្ឋមន្ត្រីបន្ថែមថាមានធ្លាក់ចុះជាបន្តបន្ទាប់នៃអត្រាស្លាប់របស់មាតា ទារកនិងកុមារ និងអត្រាឈឺ និងអត់ស្លាប់ដោយជំងឺឆ្លងដូចជា ជំងឺអេដស៍ របេង គ្រុនចាញ់ និងគ្រុនឈាមជាដើម ជាពិសេសអាចម្ចាស់ការគ្រប់គ្រងបានល្អនូវហានិភ័យនៃជំងឺកូវីដ-១៩។ ក្នុងឱកាសនោះរដ្ឋមន្ត្រីបញ្ជាក់ថាចាប់តាំងពីកម្ពុជាបានរកឃើញករណីឆ្លងដំបូងរាជរដ្ឋាភិបាលក្នុងស្មារតីបុរសកម្មការទទួលខុសត្រូវខ្ពស់ និងចក្ខុវិស័យវែងឆ្ងាយក្រោមការដឹកនាំដ៏ប៊ិនប្រសប់ ម៉ឺងម៉ាត់ ហើយនិងប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រយន្តការនិងវិធានការចាំបាច់នានាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីគ្រប់គ្រង និងទប់ស្កាត់ការចម្លងរាតត្បាតនៃកូវីដ-១៩ នៅក្នុងសហគមន៍ ជាពិសេសសម្រាប់ការរស់នៅ និងបើកដំណើរការសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ជាជំហានៗ តាមគន្លងប្រក្រតីភាពថ្មី។ កម្ពុជាសម្រេចបានជោគជ័យក្នុងយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន ទាំងដូសជំរុញ ដើម្បីបង្កើតនូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ និងការគ្រប់គ្រងបានល្អកម្រិតហានិភ័យ លើសុខភាពសាធារណៈទោះបីការឆ្លងរាលដាលក្នុងសហគមន៍នៅតែបន្តកើតមានក៏ដោយ។ លោករដ្ឋមន្ត្រី ម៉ម ប៊ុនហេង បានកោតសរសើរដោយស្មោះចំពោះមន្ត្រីរាជការបុគ្គលិកសុខាភិបាលទាំងអស់ដែលបានខិតខំពុះពារឧបសគ្គ និងការលំបាកនានាដើម្បីពង្រីកការផ្តល់សេវាអប់រំសុខភាព ពិនិត្យ ថែទាំ និងព្យាបាលមានគុណភាពជូនប្រជាពលរដ្ឋយើងនៅគ្រប់ភូមិសាស្ត្រទូទាំងប្រទេស ជាពិសេសនៅតាមប៉ុស្តិ៍សុខភាពនិងមណ្ឌលសុខភាពក្នុងតំបន់ជនបទ។ ទន្ទឹមគ្នានេះលោករដ្ឋមន្ត្រីក៏បានវាយតម្លៃខ្ពស់ចំពោះការឧបត្ថម្ភ គាំទ្រនិងកិច្ចសហការពីរដ្ឋបាលមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ គ្រប់ជាន់ថ្នាក់ ការចូលរួមយ៉ាងសកម្មពីសហគមន៍ និងភាពជាដៃគូជាមួយផ្នែកឯកជន ការគាំទ្រថវិកានិងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនិងវឌ្ឍនភាពនៃ វិស័យផ្សេងទៀតបានរួមចំណែកយ៉ាងសំខាន់ដល់វឌ្ឍនភាពនៃវិស័យសុខាភិបាលក្នុងឆ្នាំ២០២១ ជាពិសេសការខិតខំប្រឹងប្រែងរួម និងកៀងគរធនធានដែលមានដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។

### ២.វិស័យអប់រំ និងបណ្តុះបណ្តាល

វិស័យអប់រំ ដែលជាឫសគល់ដ៏ចម្បងរបស់គ្រប់ជាតិសាសន៍ទាំងការទ្រទ្រង់ និងការអភិវឌ្ឍត្រូវបានបំផ្លាញដល់ឫសគល់ ដោយសារសង្គ្រាម៥ឆ្នាំ និង របបខ្មែរក្រហម ប៉ុល ពត ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយថ្ងៃរំដោះជាតិ៧មករា ឆ្នាំ១៩៧៩ ដើម្បីស្រោចស្រង់ប្រទេសពីឋាននរកពីផេះផង់ឱ្យមានសម្រស់ឡើងវិញ សម្តេច ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាបានបង្កើតទស្សនវិស័យវែងឆ្ងាយមួយគឺ « អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះ »។ មកដល់ដំណាក់កាលក្រោយឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ន (២០២២) ទោះបីគុណភាពវិស័យអប់រំនៅកម្ពុជានៅមានកម្រិតមិនទាន់ដល់ស្តង់ដារអន្តរជាតិដែលគេទទួលយកបាន១០០% ប៉ុន្តែកម្រិតនៃការបើកទូលាយឬការបង្កើតឱកាសឱ្យកុមារា កុមារីសិស្សានុសិស្សនៅទីជនបទបានចូលរៀនត្រូវបានពង្រីកតាមគោលដៅរបស់រាជរដ្ឋាភិបាលនិងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា គឺសិស្សនៅកម្ពុជាត្រូវតែបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី៩ ដោយឥតបង់ថ្លៃ។ សិស្សនិស្សិតកម្ពុជាអាចទទួលបានពិន្ទុល្អប្រសើរពីការប្រកួតប្រជែងផ្នែកខួរក្បាលលើឆាកអន្តរជាតិ។ សិស្សពូកែកម្ពុជាទទួលបានពានរង្វាន់អន្តរជាតិផងដែរ។សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមានទស្សនវិស័យ ចក្ខុវិស័យ បង្ហិតគម្លាតខួរក្បាលរវាងអ្នកទីក្រុងនិងអ្នកជនបទស្រុកស្រែឱ្យនៅប្រហាក់ប្រហែលគ្នានិងដែលចាត់ទុកវិស័យអប់រំគឺជាក្បាលម៉ាស៊ីន គឺជាឧបករណ៍នៃការផលិតធនធានមនុស្សនិងការកសាងអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាពបានពង្រីកនិងពង្រាយសាលារៀនតាមរយៈបង្កើតអនុវិទ្យាល័យតាមបណ្តាឃុំ សង្កាត់ គឺឃុំមួយអនុវិទ្យាល័យមួយ ឬស្រុកមួយមានវិទ្យាល័យមួយ ឬពីរទៅតាមទំហំ វិសាលភាព ឬចំនួនប្រជាជនសរុប។ នៅចុងខែមេសា ឆ្នាំ២០២១ សាកលវិទ្យាល័យមួយឈ្មោះ ពុទ្ធិសាស្ត្រត្រូវបានអះអាងថាបានក្លាយជាសាកលវិទ្យាល័យដំបូងគេនៅកម្ពុជាដែលមានវត្តមានក្នុងតារាងចំណាត់ថ្នាក់នៃការអប់រំកម្រិតឧត្តមសិក្សាល្អប្រសើរក្នុងឆាកអន្តរជាតិ (Times Higher Education) ។ វិស័យអប់រំកម្ពុជាទោះបីទើបតែងើបឡើងពីសង្គ្រាមឬ ត្រូវក្រុមអ្នកនយោបាយប្រឆាំង ប៉ុន្តែជាក់ស្តែងក្នុងដំណាក់កាលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ វិស័យអប់រំកម្ពុជាពុំបានជាប់គាំងឬរងផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ គឺគេអាចរៀនតាមប្រព័ន្ធអនឡាញយ៉ាងមានប្រសិទ្ធភាព។ អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា កែវ ឡុងឌី បានឱ្យដឹងដែរថាបច្ចុប្បន្នកម្ពុជាមានបុគ្គលិកសិក្សាទាំងអ្នកបង្រៀននិងអ្នកបម្រើការងារលើវិស័យអប់រំមានចំនួនសរុបជាង ១២ ម៉ឺននាក់ ក្នុងនោះអ្នកបង្រៀនមានជាង៩ម៉ឺននាក់។ ដោយសារការចូលនិវត្តន៍ និងតម្រូវការចាំបាច់នៅចុងឆ្នាំ២០២០ រាជរដ្ឋាភិបាលបានបើកផ្លូវឱ្យក្រសួងអប់រំ យុវជន និងកីឡា ជ្រើសរើសក្របខណ្ឌគ្រូបង្រៀនប្រមាណ ៣៦០០នាក់សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២១ទោះបីកម្ពុជាជួបបញ្ហាវិបត្តិ កូវីដ-១៩ក្រសួងអប់រំ យុវជន និងកីឡាសម្រេចជ្រើសរើសក្របខណ្ឌគ្រូបង្រៀនចំនួន ១៧១៤នាក់ បន្ថែមទៀតសម្រាប់ឆ្នាំ២០២២ ហើយដើម្បីបង្កើនប្រសិទ្ធភាពនៃការអប់រំរាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យអប់រំពាដង ស្មើនឹងប្រមាណ ១៨% នៃថវិកាចំណាយរបស់ជាតិសរុប។

អ្នកជំនាញក្នុងវិស័យអប់រំបានថ្លែងថា វិស័យអប់រំត្រូវមានផែនការបាញ់ឆ្ពោះទៅរកការលើកស្ទួយសេដ្ឋកិច្ចជាតិដើម្បីជំរុញប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ឧកញ៉ា ប៉ិច បូឡែន អគ្គនាយកបណ្តាញគ្រឹះស្ថានអប់រំ វេសឡាញ អេឡូខេសិនគ្រុប បានមានប្រសាសន៍ថាគ្រប់វិស័យទាំងអស់ក្នុងប្រទេសមួយអាចរីកចម្រើនទៅបានគឺត្រូវឆ្លងកាត់វិស័យអប់រំជាចម្បងរាប់ទាំង

វិស័យកសិកម្ម ឧស្សាហកម្ម សុខាភិបាល ទេសចរណ៍ សំណង់ និងវិស័យដទៃទៀត។ លោកឧកញ៉ាបន្តទៀតថា អ្នកធ្វើការងារក្នុងវិស័យអប់រំដើរតួយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់សង្គមជាតិជាពិសេសបាននិងកំពុងចូលរួមបង្កើតប្រព័ន្ធ និងបង្កើនគុណភាព អប់រំមួយដើម្បីជានា និងផ្តល់ឱកាសដល់យុវជនអាចមានការងារសមរម្យមួយ ឬអាចចេញប្រកបមុខរបរអាជីវកម្មទទួលបានជោគជ័យរួមនឹងប្រាក់ចំណូលខ្ពស់។ ដូចនេះការបង្កើនប្រាក់ចំណូលដែលបានមកពីអាជីពការងារអាជីវកម្ម និងសហគ្រិនភាពនេះហើយដែលជាលទ្ធផលនៃការអប់រំបាញ់ឆ្ពោះទៅរកការរីកចម្រើនសេដ្ឋកិច្ចដើម្បីជំរុញប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០។ ការណ៍ដែលលោកលើកយកស្ថានភាពសេដ្ឋកិច្ចមកបង្ហាញនេះគឺលោកឧកញ៉ាចង់បញ្ជាក់ថា ព្រោះវិស័យអប់រំត្រូវមានគំនិតគិតទុកជាមុនរួមនឹងផែនការសកម្មភាពច្បាស់លាស់ដើម្បីសម្រេចឱ្យបានទិសដៅសេដ្ឋកិច្ចជាតិដែលប្រជាពលរដ្ឋទទួលប្រាក់ចំណូលជាមធ្យមគុណនឹង២ដង ក្នុងអំឡុង៧ឆ្នាំទៀត។

**៣. វិស័យកសិកម្ម**

កម្ពុជាវិស័យកសិកម្មត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យសំខាន់ៗដទៃសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាខណៈវិស័យនេះកាន់តែបង្ហាញពីសក្តានុពល និងអភិវឌ្ឍន៍ខ្លួនយ៉ាងឆាប់រហ័សនារយៈពេល៥ឆ្នាំចុងក្រោយនេះ។ ទន្ទឹមនឹងវឌ្ឍនភាពនិងភាពរីកចម្រើនវិស័យកសិកម្ម ក៏បានជួបប្រទះនូវបញ្ហាប្រឈមដូចជា ការប្រែប្រួលអាកាសធាតុ ផលិតភាពនៅមានកម្រិត ការប្រកួតប្រជែងទីផ្សារ និងបញ្ហាកង្វះកម្លាំងពលកម្មជាដើម។ បន្ថែមលើបញ្ហាទាំងនេះ វិស័យកសិកម្មក៏បាននឹងកំពុងជួបនូវបញ្ហាប្រឈមជាបន្តបន្ទាប់ដោយសារតែឥទ្ធិពលនៃវិបត្តិកូវីដ១៩ និងការអូសបន្លាយសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ផងដែរ។ ក៏ប៉ុន្តែបើទោះជាបែបនេះក្តី ក្រុមអ្នកជំនាញក្នុងវិស័យកសិកម្មនៅតែបង្ហាញពីភាពរឹងមាំរបស់វិស័យនេះក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជាតាមរយៈលំហូរនៃការនាំចេញផលិតផលកសិកម្មជាបន្តបន្ទាប់ទៅកាន់ទីផ្សារអន្តរជាតិពិសេសនៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យបណ្តាទីផ្សារអន្តរជាតិកាន់តែស្គាល់ច្បាស់ពីគុណភាពផលិតផលកសិកម្មរបស់កម្ពុជា។ វិស័យកសិកម្ម នៅតែជាវិស័យសំខាន់ដែលជួយផ្តល់ការងារជូនប្រជាពលរដ្ឋដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ ក្នុងឆ្នាំ២០២១ វិស័យកសិកម្មបានចូលរួមចំណែកក្នុងសេដ្ឋកិច្ចជាតិប្រមាណ២៤% នៃផលិតផលក្នុងស្រុកសរុបដែលមានកំណើនតម្លៃបន្ថែមចំនួន ៤,៧%។ ថ្លែងនាឱកាសសន្និសីទសារព័ត៌មានដែលធ្វើឡើងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម ស្រី វុឌ្ឍី អគ្គលេខាធិការ និងជាអ្នកនាំពាក្យក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានបង្ហាញពីភាពរឹងមាំ និងភាពធន់របស់វិស័យកសិកម្ម កម្ពុជានារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះពិសេសក្នុងបរិបទនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩តែម្តង ក្នុងការជំរុញនូវផលិតភាពក្នុងវិស័យកសិកម្មកម្ពុជានិងជំរុញការនាំចេញកសិផលទៅកាន់ទីផ្សារអន្តរជាតិ។ បើតាមឯកឧត្តម ស្រី វុឌ្ឍី គិតចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ ការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានកំណើន ៦៤% ដោយនៅឆ្នាំ២០១៧ ការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានប្រមាណ ៥លានតោនប៉ុណ្ណោះក៏ប៉ុន្តែនៅឆ្នាំ២០២១ ការនាំចេញផលិតផលកសិកម្មមានរហូតដល់៨លានតោន។ ឯកឧត្តម ងិន ឆាយ អគ្គនាយកដ្ឋានកសិកម្មបានកត់សម្គាល់ឃើញថាសន្ទុះនៃការនាំចេញកសិផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិមានកំណើនជាបន្តបន្ទាប់ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះពិសេសការនាំចេញទៅទីផ្សារចិនតែម្តង។

បើតាម ឯកឧត្តម ងិន ឆាយ បច្ចុប្បន្នកម្ពុជាអាចនាំផលិតផលកសិកម្មចំនួន៣៥មុខហើយទៅកាន់ទីផ្សារចិន ខណៈមៀនប៉ៃលិនគឺជាផលិតផលថ្មីមួយមុខទៀតដែលកម្ពុជាអាចនឹងនាំចេញទៅប្រទេសចិនក្នុងពេលឆាប់ៗខាងមុខក៏ប៉ុន្តែបើទោះជាបែបនេះក្តីមន្ត្រីជាន់ខ្ពស់កសិកម្មរូបនេះ ក៏បានគូសបញ្ជាក់ផងដែរថារយៈពេលកន្លងមកវិស័យកសិកម្ម ក៏បានជួបប្រទះនូវបញ្ហាមួយចំនួនដែរ ពិសេសអំឡុងនៃការរាតត្បាតជំងឺកូវីដ១៩ដែលធ្វើឱ្យផលិតផលកសិកម្មមួយចំនួនត្រូវបានកកស្ទះដូចជា ផ្លែមៀនប៉ៃលិន និងផ្លែស្វាយស្រស់ជាដើម។ បើតាមការបញ្ជាក់ពីឯកឧត្តម ងិន ឆាយ ការអនុវត្តគោលការណ៍គ្មានកូវីដ១៩របស់រាជរដ្ឋាភិបាលចិនបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការនាំចេញផលិតផលកសិកម្មកម្ពុជា ដូច្នេះដើម្បីដោះស្រាយបញ្ហានេះភាគីកម្ពុជា និងចិន បាននិងកំពុងពិភាក្សាគ្នាដើម្បីសម្រួលដល់ការដឹកជញ្ជូន និងនាំចូលផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារចិនដោយមិនចាំបាច់ឆ្លងកាត់ប្រទេសវៀតណាម។ ដោយឡែកលោក អួន ស៊ីឡុត ប្រធានសមាគមន៍ស្វាយចន្ទីកម្ពុជាបានកត់សម្គាល់ឃើញថានារយៈពេលចុងក្រោយនេះ វិស័យកសិកម្មកម្ពុជាពិតជារួមចំណែកយ៉ាងសំខាន់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចកម្ពុជាក៏ប៉ុន្តែវិស័យនេះក៏បានរងនូវបញ្ហាប្រឈមដូចជា ការប្រែប្រួលអាកាសធាតុ ទីផ្សារគ្មានស្ថិរភាព និងថ្លៃដើមផលិតកើនខ្ពស់។ បន្ថែមលើនោះបញ្ហាថយចុះនៃកម្លាំងពលកម្មក្នុងផលិតកម្មដំណាំស្វាយចន្ទីក៏នៅតែជាក្តីព្រួយបារម្ភក្នុងខ្សែចង្វាក់ផលិតកម្មដំណាំស្វាយចន្ទីខណៈបច្ចុប្បន្នមានកសិករមួយចំនួនបានបោះបង់ការដាំដុះស្វាយចន្ទីជាបណ្តើរៗព្រោះកត្តាកង្វះកម្លាំងពលកម្មក្នុងការចំណាយលើថ្លៃដើមផលិតកាន់តែខ្ពស់និងតម្លៃស្វាយចន្ទីគ្មានស្ថិរភាព។ បើតាមលោក អួន ស៊ីឡុត នៅឆមាសទី១ឆ្នាំ២០២២នេះ កម្ពុជាបាននាំចេញគ្រាប់ស្វាយចន្ទី ទៅប្រទេសវៀតណាមជាង ៦១ម៉ឺនតោន គិតជាទឹកប្រាក់ជាង៩០០លានដុល្លារ មានការថយចុះ ៤៤% បើប្រៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២១។ ជ្បិតថាបរិមាណនៃការនាំចេញគ្រាប់ស្វាយចន្ទីមានការថយចុះតែប្រធានសមាគមន៍ស្វាយចន្ទីកម្ពុជាបានអះអាងថាតម្លៃស្វាយចន្ទីឆ្នាំនេះហាក់ប្រសើរជាងឆ្នាំ២០២១ ដោយគ្រាប់ស្វាយចន្ទីស្ងួតនៅឆ្នាំនេះមានតម្លៃចន្លោះពី១ ៣៥០ដុល្លារទៅ១៧០០ដុល្លារក្នុង១តោន។ បើទោះជាបែបនេះក្តី ក្រុមអ្នកជំនាញក្នុងវិស័យកសិកម្មក៏បានបង្ហាញពីការព្រួយបារម្ភខ្លះដែរពីបញ្ហាប្រឈមដែលបាននិងកំពុងកើតមាននៅក្នុងវិស័យនេះដូចជា កត្តាប្រែប្រួលអាកាសធាតុ ផលិតភាពកសិកម្មរបស់កសិករខ្នាតតូចនៅមានកម្រិតចំណេះដឹងរបស់កសិករផ្នែកបច្ចេកទេសកសិកម្មទំនើបនៅមានកម្រិត ការប្រកួតប្រជែងទីផ្សារ ការកើនឡើងថ្លៃដើមផលិតដូចជាថ្លៃប្រេង ជីគីមី ថ្លៃដឹកជញ្ជូន ឡូជីស្ទិក ឡើងខ្ពស់ជាដើមនៅតែជាបញ្ហាប្រឈមសម្រាប់វិស័យកសិកម្មកម្ពុជានៅឡើយ។ យ៉ាងណាក៏ដោយយោងតាមរបាយការណ៍របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ នៅឆ្នាំ២០២១កម្ពុជាបាននាំចេញផលិតផលកសិកម្មសរុប៨លានតោនទៅកាន់ទីផ្សារអន្តរជាតិ និងចូលរួមចំណែកក្នុងសេដ្ឋកិច្ចជាតិប្រមាណ២៤%នៃផលិតផលក្នុងស្រុកសរុប។ដោយឡែកការចូលរួមពីអនុវិស័យក្នុងផលិតផលក្នុងស្រុកសរុបរួមមាន ផលិតកម្មដំណាំ ៥៧%,កៅស៊ូ ៥៧%,ផលិតកម្មសត្វ១១% ,ជលផល ២៤%, និងព្រៃឈើ ៧% ។

### ៤.វិស័យឧស្សាហកម្ម កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង

វិស័យឧស្សាហកម្មនៅកម្ពុជាមានការរីកលូតលាស់ទៅមុខ ទោះបីស្ថិតនៅក្នុងគ្រាដែលកម្ពុជាកំពុងប្រឈមនឹងបញ្ហាកូវីដ-១៩ក៏ដោយ។ ក្រោមការដឹកនាំរបស់ប្រមុខថ្នាក់ដឹកនាំកម្ពុជា បានធ្វើឱ្យកម្ពុជាមានលក្ខណៈពិសេសក្នុងការបន្តលូតលាស់នូវវិស័យឧស្សាហកម្មរបស់ខ្លួននិងភាពល្អប្រសើរនូវលទ្ធភាពក្នុងការបើកចំហប្រទេស ទាំងសង្គម និងសេដ្ឋកិច្ចបានពេញលេញ។ ទាំងនេះគឺដោយសារតែកម្ពុជាមានទំនាក់ទំនងអន្តរជាតិការបរទេសល្អជាមួយចិន ដែលជាប្រទេសផ្គត់ផ្គង់វត្ថុធាតុដើមនៅទូទាំងពិភពលោក។ នេះជាការលើកឡើងរបស់ឯកឧត្តមហេង សុខគង់ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យនៃក្រសួងឧស្សាហកម្ម បច្ចេកវិទ្យាវិទ្យាសាស្ត្រ និងនវានុវត្តន៍។ ថ្លែងក្នុងសន្និសីទសារព័ត៌មានឯកឧត្តមហេង សុខគង់ បានឱ្យដឹងអំពីសមិទ្ធផលសម្រេចរយៈពេល៥ឆ្នាំរបស់ក្រសួង ទោះបីជាស្ថិតក្នុងស្ថានភាពលំបាកក្តីក៏វិស័យឧស្សាហកម្មនៅកម្ពុជាបន្តការរីកចម្រើនទៅមុខឥតឈប់ឈរ។ ក្រោមមគ្គុទេសក៍ដឹកនាំរបស់សម្តេច ហ៊ុន សែន កម្ពុជាមានលក្ខណៈពិសេសកត្តារួម គឺកត្តាសុខសន្តិភាព កត្តាទី២គឺទំនាក់ទំនងអន្តរជាតិល្អនេះហើយដែលធ្វើឱ្យកម្ពុជាមានលទ្ធភាពទទួលបានវ៉ាក់សាំងពីគ្រប់ប្រទេសជាមិត្តទាំងអស់ ដែលជាការបង្កើតសហគមន៍មានភាពស៊ាំ និងមានភាពល្អប្រសើរដែលអាចឱ្យកម្ពុជាមានលទ្ធភាពក្នុងការបើកចំហប្រទេសទាំងសង្គមនិងសេដ្ឋកិច្ចបានពេលលេញ។ ទាំងនេះ គឺជាការបង្កើតនូវជំនឿទុកចិត្តមួយទៀតទាំងសម្រាប់អ្នកដែលបញ្ជាទិញ និងសម្រាប់អ្នករោងចក្រសហគ្រាសដែលអ្នកវិនិយោគមិនបារម្ភថាអាចបិទទ្វារ។ ឯកឧត្តម ហេង សុខគង់ បានបញ្ជាក់ថានៅក្នុងដំណាក់កាលដ៏សំខាន់គឺនៅចុងឆ្នាំ២០១៩ វីរុសកូវីដ១៩ គឺចេញពីតំបន់វូហាន ប្រទេសចិន ហើយនៅពេលនោះប្រទេសចិនបានចាប់ផ្តើមបិទទ្វារធ្វើឱ្យបណ្តារោងចក្រនៅប្រទេសចិនគឺបិទទ្វារដូចគ្នា។ រោងចក្រនៅប្រទេសចិន គឺជាប្រភពដើមនៃការផ្គត់ផ្គង់វត្ថុធាតុដើមនៅទូទាំងពិភពលោក។ រោងចក្រនៅកម្ពុជា កាត់ដេរសម្លៀកបំពាក់ កាបូប ស្បែកជើង គឺត្រូវការវត្ថុធាតុដើម ៨០%ពីប្រទេសចិន និង២០%ពីប្រទេសវៀតណាម ហើយនៅក្នុងដំណាក់កាលនោះនៅឆ្នាំ២០២០សល់តែ៣-៤ខែប៉ុណ្ណោះកម្ពុជានឹងអស់វត្ថុធាតុដើមសម្រាប់ផលិត ប៉ុន្តែដោយសារកម្ពុជាមានទំនាក់ទំនងល្អជាមួយចិនជាពិសេសកម្ពុជាបានធ្វើការទំនាក់ទំនងទៅខាងក្រសួងឧស្សាហកម្ម និងបច្ចេកវិទ្យាព័ត៌មានរបស់ចិន ដើម្បីធ្វើយ៉ាងណាឱ្យមានការផ្គត់ផ្គង់ជាលក្ខណៈពិសេសមកកម្ពុជា។ ឯកឧត្តម ហេង សុខគង់ បានបន្តថានៅក្នុងដំណាក់ដែលមានវិបត្តិកូវីដជាសកលកម្ពុជាទទួលបានវត្ថុធាតុដើមមុនគេបំផុតនៅលើពិភពលោកដែលនេះគឺជាការបង្កើននូវជំនឿទុកចិត្តបន្ថែមទៀតសម្រាប់អ្នកវិនិយោគិនមិនព្រួយបារម្ភទាំងកង្វះនៃវត្ថុធាតុដើម ទាំងមិនព្រួយបារម្ភការបិទទ្វាររោងចក្រទាំងមិនបារម្ភពីការបញ្ជាទិញ កត្តាទាំងអស់នេះធ្វើឱ្យអ្នកវិនិយោគបណ្តាក់ទុនបន្ថែមនៅកម្ពុជា។ ត្រឹមតែពាក់កណ្តាលនៃដើមឆ្នាំ២០២២នេះ កម្ពុជាបានបើករោងចក្រថ្មីចំនួន ១១២។ ឯកឧត្តម បានឱ្យដឹងទៀតថាឧស្សាហកម្មផលិតកង់កម្ពុជាបាននាំចេញទៅពិភពលោកគឺទទួលបានចំណាត់ថ្នាក់លេខ៥ ហើយចំណាត់ថ្នាក់លេខ១ ខាងនាំចេញទៅសហគមន៍អឺរ៉ុប ដែលត្រឹមតែក្នុងរយៈពេលពាក់កណ្តាលឆ្នាំ២០២២នេះ កម្ពុជាបានផលិត និងលក់បានសរុបរហូតដល់ ៥២០លានដុល្លារសហរដ្ឋអាមេរិក។ បើនិយាយពីកំណើនប្រៀបធៀបនៅឆ្នាំ២០២១ កម្ពុជាលក់កង់បានតែ ១៦៦លានដុល្លារសហរដ្ឋអាមេរិក ដែលសង្កេតឃើញថាកំណើននៃការនាំចេញកង់នេះ បាននាំមកនូវចំណូលដល់ជាតិយ៉ាងច្រើន។ ទន្ទឹមនេះការបង្កើតនូវរោងចក្រថ្មីចំនួន ១១២នៅកម្ពុជា ក៏បានបង្កើតការងារដល់ពលរដ្ឋ ជាង៧ម៉ឺននាក់និងមានដើមទុនវិនិយោគរហូតដល់ជាង

១១៨៩ លានដុល្លារ សហរដ្ឋអាមេរិក។ រាជរដ្ឋាភិបាលក្នុងករណីដែលសេដ្ឋកិច្ចមានកំណើន ទាំងប្រាក់ខែមន្ត្រីរាជការ ប្រាក់ខែកម្មករ កម្មាការិនី នឹងនៅតែបន្តឡើងដើម្បីសម្រេចចក្ខុវិស័យឆ្នាំ២០៣០ដើម្បីប្រែក្លាយកម្ពុជាពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅចំណូលមធ្យមកម្រិតខ្ពស់បានលុះត្រាប្រជាពលរដ្ឋមានកម្រិត GDP ចំណូលពី ៦០០០-៧០០០ដុល្លារក្នុងមួយឆ្នាំ ហើយបន្តដំឡើងប្រាក់ខែនៅឆ្នាំ២០៥០ ដោយរាជរដ្ឋាភិបាលបានគិតគូរពីស្ថានភាពសេដ្ឋកិច្ចដើម្បីធានាដល់មីក្រូសេដ្ឋកិច្ចរឹងមាំជួយដល់ប្រទេសកម្ពុជាឱ្យមានការរីកចម្រើនទៅមុខនិងសម្រេចចក្ខុវិស័យដែលកម្ពុជាបានដាក់ចេញ ។

វិស័យកាត់ដេរសម្លៀកបំពាក់នៅកម្ពុជានៅត្រីមាសទី១ ឆ្នាំ២០២២នេះ នៅតែរក្សាបានកំណើននៃការនាំចេញក្នុងអត្រា២៥ភាគរយ ជាមួយទឹកប្រាក់ចំនួន ៣១៥៥លានដុល្លារ។ ក្នុងនោះសម្លៀកបំពាក់ចំនួន២១៣៧លានដុល្លារ មានកំណើន២០ភាគរយ ស្បែកជើងមានចំនួន ៤២១លានដុល្លារ កើនឡើង ៣៣ភាគរយ និងផលិតផលធ្វើដំណើរនិងកាបូបមានចំនួន៤៦៨លានដុល្លារ មានការកើនឡើង៤៦ភាគរយខណៈដែលផលិតផលវាយនភណ្ឌផ្សេងៗទៀតមានចំនួន១២៨លានដុល្លារកើនឡើង១១ភាគរយ។ ឯកឧត្តម **ប៉ាន់ សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានថ្លែងកាលពីពេលថ្មីៗនេះថាសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានចូលរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដទៃទៀតក្នុងការចរចាបើកទីផ្សារបន្ថែមក៏ដូចជាការកសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូបកម្ពុជាឆ្នាំ២០២២-២០២៧ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងប្រែក្លាយវិស័យនេះទៅជាឧស្សាហកម្មដែលមានចីរភាពផ្នែកបរិស្ថានមានភាពធន់ និងតម្លៃបន្ថែមច្រើនព្រមទាំងមានភាពប្រកួតប្រជែងខ្ពស់ក្នុងតំបន់ដ៏ដូចជាពិភពលោក។

**៣.២.២ អនុសាសន៍របស់លោកឯកឧត្តម អ៊ិត សំហេង**

ការវិនិយោគលើការអភិវឌ្ឍជំនាញព្រមទាំងមុខរបរ និងការងាររបស់យុវជននៅថ្ងៃនេះ មានន័យថាជាការវិនិយោគសង្គមរបស់យើងនាបច្ចុប្បន្ននិងអនាគត។ ហើយការវិនិយោគនេះទៀតសោតតម្រូវឱ្យមានការយកចិត្តទុកដាក់លើគុណភាពនិងបរិមាណការងារ ។ នេះជាប្រសាសន៍លើកឡើងរបស់ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងឱកាសដែលឯកឧត្តមអញ្ជើញជាអធិបតីបើកវេទិកាដៃគូស្តីពីជំនាញនិងអនាគតនៃការងារដែលត្រូវបានរៀបចំឡើងដោយអង្គការអន្តរជាតិខាងការងារ (ILO) សហការជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើតាមរយៈប្រព័ន្ធវីដេអូអនឡាញនារសៀលថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ដោយមានការអញ្ជើញចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងតំណាងកម្មករនិយោជិតនិងនិយោជកនិងដៃគូអភិវឌ្ឍន៍ក្នុងការចែករំលែកចំណេះដឹងបទពិសោធន៍ និងវិធីសាស្ត្រល្អៗពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធបណ្តុះបណ្តាលជំនាញ និងប្រព័ន្ធរៀនសូត្រពេញមួយជីវិត។ កិច្ចពិភាក្សានេះដែរនឹងជាធាតុចូលដ៏សំខាន់សម្រាប់ដំណើរការកសាងអនាគតការងារនៅកម្ពុជាប្រកបដោយគុណភាព និងចីរភាពស្របទៅនឹងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានកំណត់ថា "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"។ កម្មវិធីនេះត្រូវបានស្ថាបនាឱ្យចេញជារូបរាងតាមរយៈភាពជាដៃគូរដែលមានលក្ខណៈនវានុវត្តន៍និងប្រសិទ្ធភាពទាំងក្នុងប្រទេសនិងអន្តរជាតិដោយប្រើប្រាស់អភិក្រមចម្រុះដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា និងសមស្របទៅតាមបរិបទជាក់ស្តែង។ កម្មវិធីនេះគឺជាឱកាសដើម្បីឱ្យយើងទាំងអស់គ្នារួមកម្លាំងគ្នា និងពង្រីកវិសាលភាពនៃសកម្មភាព និងឥទ្ធិពលតាម

រយៈអន្តរាគមន៍នវានុវត្តន៍ ដែលប្រកបដោយប្រសិទ្ធភាពនិងផ្អែកលើភស្តុតាងជាក់ស្តែងវាក៏ផ្តល់នូវគំរូដ៏ល្អបំផុតសម្រាប់ការកសាងភាពជាដៃគូរួមគ្នារវាងរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍វិស័យឯកជន និងអង្គការមិនរកប្រាក់ចំណេញ។ ឯកឧត្តមបណ្ឌិត**អ៊ិត សំហេង** គូសបញ្ជាក់ថាការវិវត្តនៃបច្ចេកវិទ្យា និងសកលភាវូបនីយកម្មព្រមទាំងបម្រែបម្រួលប្រជាសាស្ត្រ និងអាកាសធាតុគឺជានិន្នាការធំៗដែលកំពុងនាំមកនូវការផ្លាស់ប្តូរក្នុងពិភពនៃការងារហើយការណ៍នេះក៏ផ្តល់នូវកាលានុវត្តភាពថ្មីៗជាច្រើនផងដែរ។ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះក៏នាំមកនូវបញ្ហាប្រឈមសម្រាប់ប្រជាជនក្នុងការទទួលបានការបង្កើនជំនាញក៏ដូចជាការបង្កបញ្ហាប្រឈមដល់វិស័យឯកជនក្នុងការសម្របខ្លួនទៅតាមការផ្លាស់ប្តូរទាំងនេះប្រកបដោយនិរន្តរភាពផងដែរ។ ជាមួយគ្នានេះដែរក្រសួងបាននឹងកំពុងជំរុញការអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ជាពិសេសយុទ្ធសាស្ត្រគន្លឹះទី២ "ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ" ដើម្បីកសាងបានកម្លាំងពលកម្មដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ គំនិតច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុងស្រុក និងក្នុងតំបន់។ ឯកឧត្តមរដ្ឋមន្ត្រីក៏បានវាយតម្លៃខ្ពស់ចំពោះការណ៍ដែលអង្គការ ILO បាននិងកំពុងអនុវត្ត គំនិតផ្តួចផ្តើមនវានុវត្តន៍នៅកម្ពុជាដើម្បីបំផុសឱ្យមានការអនុវត្តវិធានការដាក់លាក់សំដៅ៖ លើកកម្ពស់ជំនាញសម្រាប់ការងារបៃតងជម្រុញបរិវត្តកម្មឌីជីថលនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ផ្តល់ការគាំទ្រដល់យុវជនដើម្បីឱ្យពួកគេអាចអភិវឌ្ឍន៍ និងពង្រឹងជំនាញសម្រាប់អាជីពរបស់ពួកគេ គាំទ្រដល់ពលករទេសន្តប្រវេសន៍ដែលបានធ្វើមាតុភូមិនិវត្តន៍ឱ្យធ្វើសមាហរណកម្មក្នុងទីផ្សារការងារឡើងវិញ។ គួរជម្រាបជូនផងដែរថាដើម្បីឆ្លើយតបទៅនឹងបញ្ហាជំនាញនិងអនាគតនៃការងារ ក៏ដូចជាការឆ្លើយតបទៅនឹងការរីករាតត្បាតនៃជំងឺកូវីដ១៩នេះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញរួមមកហើយនូវគោលនយោបាយសំខាន់ៗមួយចំនួនដូចជាគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ក្របខណ្ឌយុទ្ធសាស្ត្រ កម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣ និងគោលនយោបាយជាតិស្តីពីពលករប្រវេសន៍ឆ្នាំ២០១៩-២០២៣ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

### ៣.២.៣ អនុសាសន៍របស់លោក ថោង ខុន

ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានដាក់ចេញនូវអនុសាសន៍ណែនាំបន្ថែមចំនួន៥ចំណុចដល់សមាគមន៍ទេសចរណ៍កម្ពុជា(CATA)ដើម្បីជាធាតុចូលសម្រាប់សកម្មភាពការងាររបស់សមាគមន៍នាឆ្នាំ២០២៣ខាងមុខនេះនិងឆ្នាំបន្តបន្ទាប់ទៀតសំដៅធ្វើយ៉ាងណាឱ្យការអនុវត្តន៍ការងារកាន់តែទទួលបាននូវភាពជោគជ័យ។ ឯកឧត្តមរដ្ឋមន្ត្រី ថោង ខុន បានដាក់ចេញនូវអនុសាសន៍ណែនាំយ៉ាងដូចនេះនាល្ងាចថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ នាឱកាសដែលោកអញ្ជើញជាអធិបតីក្នុងកម្មវិធីរាត្រីជួបដៃគូអាជីវកម្មមិត្តអ្នកជំនួញប្រចាំឆ្នាំរបស់សមាគមទេសចរណ៍កម្ពុជាដែលបានរៀបចំឡើងសណ្ឋាគារ Raffles Hotel Le Royal និងដោយមានការចូលរួមពីលោកជំទាវ ឆាយ ស៊ីវលីន ប្រធានសមាគមទេសចរណ៍កម្ពុជារួមទាំងមានសមាជិកសមាគមទេសចរណ៍កម្ពុជាជាច្រើនរូបទៀតផងដែរ។

**អនុសាសន៍ណែនាំសំខាន់ៗរបស់ឯកឧត្តមរដ្ឋមន្ត្រី ថោង ខុន ក្នុងកម្មវិធីរាត្រីជួបដៃគូអាជីវកម្មមិត្ត អ្នកជំនួញប្រចាំឆ្នាំរបស់សមាគមទេសចរណ៍កម្ពុជា រួមមាន៖**

១. សូមសមាគមន៍ផ្តល់កិច្ចសហការបន្ថែមជាមួយនិងក្រសួងទេសចរណ៍ក្នុងការជំរុញការរៀបចំ **«ឆ្នាំទស្សនាកម្ពុជា២០២៣ ក្រោមពាក្យស្លោក កីឡា និងព្រឹត្តការណ៍ Sport and Festival»** ឱ្យបានជោគជ័យ។ បច្ចុប្បន្នក្រសួងទេសចរណ៍កំពុងរៀបចំវិធានការគោលនយោបាយអនុវត្តឆ្នាំទស្សនាកម្ពុជា ២០២៣នេះ និងគ្រោងដាក់ឱ្យអនុវត្តក្នុងពេលឆាប់ៗនេះ។

២. សូមរៀបចំសកម្មភាពផ្សព្វផ្សាយ និងទាក់ទាញទេសចរណ៍អន្តរជាតិឡើងវិញឱ្យបានឆាប់រហ័ស ដើម្បីចាប់យកឱកាសទីផ្សារក្នុងតំបន់និងសកល ខណៈនិន្នាការធ្វើដំណើរនៅតែមានសន្ទុះខ្លាំងរួមមានទីផ្សារក្នុងតំបន់អាស៊ាន ចិន និងឥណ្ឌាជាដើមពិសេសសូមចូលរួមផ្សព្វផ្សាយឱ្យបានសកម្មជាមួយដៃគូក្រៅប្រទេស ពីសកម្មភាពឆ្ពោះទៅកាន់ការរៀបចំព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ក្នុងឆ្នាំ ២០២៣នៅកម្ពុជា។

៣. សូមឱ្យសមាគមន៍បន្តជំរុញឱ្យបុគ្គលិករបស់អាជីវកម្មទេសចរណ៍ចូលរួមវគ្គបណ្តុះបណ្តាលដើម្បីទទួលបានជំនាញថ្មី និងអភិវឌ្ឍន៍ជំនាញដែលមានស្រាប់ និងចូលរួមដល់ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ឱ្យស្របតាមស្តង់ដា។

៤. សូមជំរុញឱ្យអាជីវកម្មទាំងអស់ដែលជាសមាជិកបន្តអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិប្រតិបត្តិស្តង់ដារ (SOP) ដាក់ចេញដោយក្រសួងទេសចរណ៍ដើម្បីឱ្យស្របតាមបរិបទនៃការរៀនរស់ជាមួយកូវីដ១៩ តាមគន្លងប្រក្រតីភាពថ្មី។

៥. សូមសមាគមន៍បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍ក្នុងការរៀបចំ សកម្មភាពផ្សព្វផ្សាយទេសចរណ៍រួមគ្នា រួមមាន៖ ការផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល និងការទទួល Farm Trip ជាដើម។ លោកយល់ថាគួរបង្កើតក្រុមការងារមួយសម្រាប់ផ្តល់កិច្ចសហការលើការងារផ្សព្វផ្សាយនេះផងដែរ។ ជាមួយគ្នានោះដែរឯកឧត្តម **ថោង ខុន** ក៏បានកោតសសើរ និងថ្លែងអំណរគុណចំពោះសមាគមទេសចរណ៍កម្ពុជា ដែលតែងតែផ្តល់កិច្ចសហការយ៉ាងសកម្ម គាំទ្រសកម្មភាពការងារនានារបស់ក្រសួងទេសចរណ៍ និងបានកសាងស្នាដៃជាច្រើនក្នុងការជំរុញនិងផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជានៅថ្នាក់ជាតិ តំបន់ និងពិភពលោក និងបានបង្ហាញជំនឿជាក់ថាក្រោមដំបូលនៃសន្តិភាព និងក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី «យើងទាំងអស់គ្នានឹងអាចឆ្លងផុតគ្រាដ៏លំបាកនេះ» និងរៀបចំឆ្ពោះទៅកាន់អនាគតថ្មីនៃវិស័យទេសចរណ៍ដូចដែលបានកំណត់ក្នុងផែនទីចង្អុលផ្លូវដំណាក់កាលទី៣ (២០២៤-២០២៥)ផងដែរ។ នាឱកាសនោះដែរលោកជំទាវ **ឆាយ ស៊ីវលីន** បានឱ្យដឹងដែរថាសម្រាប់សមាគមន៍ CATA ជាផែនការបន្ទាប់សម្រាប់ឆ្នាំ២០២៣រួមមាន៖ សមាគមន៍និងទទួលរៀបចំធ្វើ Farm Trip សម្រាប់ទីភ្នាក់ងារទេសចរណ៍មកពីបណ្តាប្រទេសអាស៊ាន ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើសេវាកម្ម និងផលិតផលទេសចរណ៍ថ្មីៗនៅកម្ពុជា បង្កើនកម្មវិធីផ្គូផ្គងដៃគូអាជីវកម្មទេសចរណ៍ជាមួយនឹងបណ្តាប្រទេសអាស៊ានដើម្បីបង្កើនទីផ្សារនិងកិច្ចសហប្រតិបត្តិការបង្កើនទំនាក់ទំនងទីផ្សារឥណ្ឌាដើម្បីអនុវត្តន៍អនុស្សរណៈយោគយល់គ្នាដែលបានព្រមព្រៀងចុះហត្ថលេខា រវាងសមាគមCATA និងរដ្ឋម៉ាត់យ៉ាប្រាដេសនៃប្រទេសឥណ្ឌា នាពេលកន្លងទៅភ្ជាប់ទំនាក់ទំនងទៅកាន់ទីផ្សារ ទេសចរណ៍ក្នុងប្រទេសឥណ្ឌាសិក្សាទីផ្សារដើម្បី

ជំរុញ និងគាំទ្រឱ្យមានការហោះហើរត្រង់កម្ពុជាទៅកាន់ប្រទេសឥណ្ឌា និងឥណ្ឌាមកកាន់កម្ពុជា, បន្តបង្កើតទីផ្សារកម្មវិធីបណ្តុះបណ្តាលវគ្គខ្លីៗឱ្យបានច្រើនដើម្បីបំពេញតម្រូវការជាក់ស្តែង, បន្តឡើងវិញនូវសកម្មភាពបញ្ជ្រាបការយល់ដឹងពីការទុកដាក់កាកសំណល់, ផ្តល់ការគាំទ្រសម្រាប់ការផលិត ផលិតផលក្នុងស្រុកសម្រាប់សហគមទេសចរណ៍ ដើម្បីទទួលបានចំណូលបន្ថែមផងដែរ។

## ៣.៣ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និងការអភិវឌ្ឍទីផ្សារការងារ

### ៣.៣.១ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាល

រាជរដ្ឋាភិបាលបានដាក់ចេញនូវសូចនាករកម្រិតយុទ្ធសាស្រ្តដើម្បីលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារការអភិវឌ្ឍលក្ខខណ្ឌការងារនិងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈទៅក្នុងផែនការយុទ្ធសាស្រ្តរយៈពេល៥ឆ្នាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នេះបើតាមការលើកឡើងរបស់លោក កត្តា អ៊ន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទីផ្សារការងារដែលមាននៅក្នុងប្រទេសកម្ពុជារួមមានដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យអប់រំ វិស័យសុខាភិបាល វិស័យធនាគារ និងវិស័យផ្សេងៗទៀត។

នាឱកាសនេះដែរលោក កត្តា អ៊ន បានគូសបញ្ជាក់ថា សូចនាករកម្រិតយុទ្ធសាស្រ្តទាំងនេះ គឺជាកិច្ចការងារអាទិភាពមួយយ៉ាងសំខាន់ដែលរាជរដ្ឋាភិបាល បន្តយកចិត្តទុកដាក់ពង្រឹងការអនុវត្ត ជាពិសេសវាបានរំលេចនៅក្នុងមុំទី១ ស្តីពីការអភិវឌ្ឍទីផ្សារការងារនៃបញ្ចកោណទី៣ស្តីពីការអភិវឌ្ឍវិស័យឯកជន និងការងារក្នុង «យុទ្ធសាស្រ្តបញ្ចកោណដំណាក់កាលទី១» របស់រាជរដ្ឋាភិបាលអាណត្តិទី៧នេះ។លោកបានពន្យល់ថាផែនការយុទ្ធសាស្រ្តទាំងនោះមានដូចជានៅក្នុងអាណត្តិនេះក្រសួងការងារនឹងបន្តយកចិត្តទុកដាក់លើការពង្រឹងការអនុវត្តច្បាប់ និងអភិវឌ្ឍន៍ក្របខណ្ឌ គតិយុត្តស្របតាមការប្រែប្រួលនៃលក្ខខណ្ឌការងារ និងការលេចឡើងនៃប្រភេទការងារថ្មីៗ ស្របតាមការវិវត្តនៃពិភពការងារ បន្តពង្រឹងយន្តការអធិការកិច្ចការងារតាមរយៈការចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះសហគ្រាស គ្រឹះស្ថានដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធ និងវិស័យការងារការលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារព្រមទាំងធានាថាលក្ខខណ្ឌការងារនៅកម្ពុជានឹងត្រូវបានអនុវត្តដោយអនុលោមតាមបទដ្ឋានការងារអន្តរជាតិនិងគោលនយោបាយពាណិជ្ជកម្មផ្សារភ្ជាប់នឹងលក្ខខណ្ឌការងារ។ លោកបានបន្តថាដូចនេះក្រសួងការងារនឹងបន្តប្តេជ្ញាចិត្តក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ការពង្រឹងយន្តការស្ថាប័ននិងតួអង្គការស្ថាប័ននិងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បរមានិងអត្ថប្រយោជន៍កម្មករនិយោជិតដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច ការលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈតាមរយៈការអនុវត្តសិទ្ធិ និងតួនាទីរបស់អង្គការវិជ្ជាជីវៈប្រកបដោយភាពស្មោះត្រង់ សុចរិត ស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈនិងភាពឆាប់រហ័សនៃការដោះស្រាយវិវាទការងារដើម្បីប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ។ បន្ថែមពីនេះ លោកកត្តា អ៊ន បានបន្តទៀតថាសូចនាករកម្រិតយុទ្ធសាស្រ្តដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្រ្តនេះរួមមានទី១៖ អត្រាសហគ្រាស គ្រឹះស្ថានដែលអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធកើនឡើងដើម្បីប្រែក្លាយ «សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ» និងធានាបាននូវអាជីវកម្មប្រកបដោយទំនួលខុសត្រូវនិងការប្រើប្រាស់ពលកម្មស្អាតស្អំ។ ទី២៖រាល់ករណីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រូវបានអន្តរាគមន៍ និងចាត់វិធានការតាមច្បាប់យ៉ាងម៉ឺងម៉ាត់ដោយ

មិនមានការលើកលែងក្នុងរយៈពេល២៤ម៉ោង។ ទី៣៖ ចំនួនកម្មករនិយោជិតទទួលរងគ្រោះថ្នាក់ការងារក្នុងចំណោមកម្មករនិយោជិតមានការថយចុះយ៉ាងតិច១០%ក្នុងមួយឆ្នាំ។ ទី៤៖ អត្រាវិវាទការងារឬការស្រាយបំភ្លឺច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលប្ដឹងឬស្នើសុំមកក្រសួងជាស្ថាប័នដំបូងកើនឡើងដើម្បីទទួលបានការជឿទុកចិត្តរបស់កម្មករនិយោជិត និយោជកនិងភាគីពាក់ព័ន្ធ។ ទី៥៖ អត្រានៃសំណើរឬបណ្ដឹងពាក់ព័ន្ធនឹងអនុសញ្ញាអន្តរជាតិខាងការងារ ត្រូវបានដោះស្រាយទាន់ពេលវេលាកើនឡើងដើម្បីរក្សាកេរ្តិ៍ឈ្មោះកម្ពុជា ជាប្រទេសដែលគោរពបទដ្ឋានអន្តរជាតិខាងការងារក្នុងខ្សែច្រវាក់ផ្គត់ផ្គង់សកល។ ទន្ទឹមនឹងនេះលោកបានគូសបញ្ជាក់ថាសូចនាករកម្រិតយុទ្ធសាស្ត្រទាំងនេះត្រូវបានដាក់ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីនឹងលើកកម្ពស់សុវត្ថិភាពរបស់កម្មករនិយោជិតនៅក្នុងរោងចក្រសហគ្រាសនិងលុបបំបាត់ពលកម្មកុមារ និងវិវាទការងារផងដែរ ។

ប្រមុខរដ្ឋាភិបាលកម្ពុជាសម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន បានថ្លែងថាស្ថានភាពទីផ្សារការងារនៅកម្ពុជាមានភាពរឹងមាំ ដោយរក្សាបាននូវអត្រាមានការងារធ្វើខ្ពស់ប្រមាណ ៩៩.៣% នៃកម្លាំងពលកម្មសរុបចំនួនប្រមាណ ១០,៨លាននាក់ និងបន្ថែមលើការរីកចម្រើន សេដ្ឋកិច្ចក្នុងប្រព័ន្ធ សេដ្ឋកិច្ចក្រៅប្រព័ន្ធក៏ជាកម្លាំងចលករដ៏សំខាន់មួយដែលបានដើរតួនាទីស្នូលក្នុងការជម្រុញកំណើនសេដ្ឋកិច្ច និងមានភាពធន់ខ្ពស់ចំពោះផលប៉ះពាល់ពីកត្តាខាងក្រៅមកលើសេដ្ឋកិច្ចជាតិ និងជីវភាពប្រជាពលរដ្ឋ។ នេះបើតាមសារលិខិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឱកាសទិវាជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៦នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣។ ក្នុងសារលិខិតសម្ដេចតេជោ ហ៊ុន សែន មានប្រសាសន៍ថាដើម្បីឆ្លើយតបទៅនឹង បញ្ហាជំនាញ និងអនាគតនៃការងាររាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជម្រុញការអនុវត្តគោលនយោបាយសំខាន់ៗមួយចំនួនដូចជាគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ គោលនយោបាយសំខាន់ជាតិស្តីអំពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្ដារ និងជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥ ផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយាន្តយន្ត និងអេឡិចត្រូនិកកម្ពុជាផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាឆ្នាំ២០២៣-២០២៧ ព្រមទាំងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍជំនាញនៅកម្ពុជាឆ្នាំ២០២៣-២០៣៥។ សម្ដេចគូសបញ្ជាក់ថាដើម្បីផ្ដល់លទ្ធភាពទទួលបានការបណ្ដុះបណ្ដាលប្រកបដោយសមធម៌ រាជរដ្ឋាភិបាលបានពង្រឹងការផ្ដល់អាហាររូបករណ៍កាន់តែច្រើនឡើង សម្រាប់យុវជនដែលបោះបង់ការសិក្សា ប្រជាពលរដ្ឋក្រីក្រ ស្ត្រីជនពិការ ជនជាតិដើមភាគតិច ជនងាយរងគ្រោះ និងកម្មករនិយោជិត។ សម្ដេចតេជោនាយករដ្ឋមន្ត្រីបន្តថាជាលទ្ធផលរយៈពេល៥ឆ្នាំចុងក្រោយនេះមានសិក្ខាសិស្សតាមនិស្សិត និងកម្មករនិយោជិតប្រមាណ៣០ម៉ឺននាក់បានទទួលការបណ្ដុះបណ្ដាលនិងបញ្ចប់ការសិក្សាដោយជោគជ័យក្នុងការទទួលបានជំនាញថ្មីនិងលើកកម្ពស់ជំនាញរបស់ខ្លួនដោយបានចាប់យកឱកាសការងារល្អៗ ក៏ដូចជាការបង្កើតមុខរបរដោយខ្លួនឯង ក្នុងការបង្កើតប្រាក់ចំណូលក្នុងគ្រួសារ និងជួយលើកស្ទួយសេដ្ឋកិច្ចជាតិបានយ៉ាងច្រើន។ ជាមួយគ្នានេះក្នុងអំឡុង

ពេលមានការរីកដុះដាលនៃជម្ងឺកូវីដ១៩បានបង្កើតកម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ពិសេសរយៈពេល៤ខែដល់កម្មករ និយោជិតនិងយុវជន ដើម្បីទទួលបានឱកាសការងារថ្មីនិងបង្កើតមុខរបរដោយខ្លួនឯងបានចំនួន ២១៥០០ នាក់ និងបណ្តុះបណ្តាលជំនាញទុនទៅដល់កម្មករនិយោជិតបានចំនួន ៦៨ ០០០នាក់។

បន្ថែមពីនេះ រាជរដ្ឋាភិបាលបានត្រៀមរៀបចំផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈដល់យុវជននៅគ្រួសារក្រីក្រ និងងាយរងគ្រោះទូទាំងប្រទេសចំនួន១លាន៥សែននាក់ ដោយរដ្ឋជានាផ្តល់ប្រាក់ឧបត្ថម្ភចាប់ពីឆ្នាំ២០២៣នេះតទៅដើម្បីផ្តល់ឱកាសឱ្យពួកគេទទួលបានជំនាញសម្រាប់យកទៅធ្វើការងារ ឬបង្កើតមុខរបរដោយខ្លួនឯង និងបំពេញតម្រូវការនៃកម្លាំងពលកម្មជំនាញសម្រាប់ការវិនិយោគថ្មីៗនៅកម្ពុជា។សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធបន្តថែរក្សាសន្តិភាពនិងស្ថេរភាពនៅកម្ពុជា ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការបន្តការអភិវឌ្ឍមូលធនមនុស្សពោរពេញដោយជំនាញនិងសមត្ថភាព ដើម្បីបង្កើនផលិតភាពប្រកួតប្រជែងកំណើនសេដ្ឋកិច្ចខ្ពស់ ការបង្កើតការងារធ្វើកាន់តែល្អនិងរក្សាការងារដែលមានស្រាប់សំដៅបន្តលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនេះ បន្តគាំទ្រក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាប្រកបដោយចំណេះដឹងសមត្ថភាពជំនាញឥរិយាបថការងារសីលធម៌វិជ្ជាជីវៈផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត។ សម្តេចតេជោក៏បានជម្រុញការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា ផែនទីបរិវត្តកម្មឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរកម្ពុជាឆ្នាំ២០២៣-២០២៧ និងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍ ជំនាញនៅកម្ពុជា។

**៣.៣.២ ការអភិវឌ្ឍទីផ្សារការងារ**

ឯកឧត្តម អ៊ិត សំហេង បានលើកឡើងថាក្រសួងបានបន្តបង្កើនឱកាសការងារក្នុងប្រទេសតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដោយបានផ្សព្វផ្សាយព័ត៌មានទីផ្សារការងារពង្រីកការផ្តល់ប្រឹក្សាយោបលមគ្គុទេសក៍ការងាររៀបចំវេទិកាការងារ និងបណ្តុះបណ្តាលជំនាញត្រៀមចូលទីផ្សារការងារជាដើម ហើយប្រជាជនក៏មានជម្រើសក្នុងការស្វែងរកឱកាសការងារក្រៅប្រទេសស្របច្បាប់ ដែលមានលក្ខខណ្ឌការងារល្អ និងប្រាក់ចំណូលខ្ពស់ផងដែរ។ក្រៅពីនេះក្រសួងការងារនៅតែបន្តលើកកម្ពស់សុវត្ថិភាព ការងារនិងសុខភាពកម្មករនិយោជិតតាមរយៈការរៀបចំច្បាប់ការកែលម្អគុណភាពមធ្យោបាយដឹកជញ្ជូនឱ្យកាន់តែមានសុវត្ថិភាព និងតាមស្តង់ដារបច្ចេកទេសជំរុញការចូលរួមរបស់និយោជកក្នុងការគាំទ្រដល់ទារកដ្ឋានសហគមន៍ ដែលនៅក្បែរតំបន់រោងចក្រជាដើម។ មកទល់ពេលនេះកម្ពុជាកំពុងអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារនិងមន្ត្រីសាធារណៈ។ចំពោះវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក្រសួងបានអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញ និងខិតខំអនុវត្តកម្មវិធីនេះដោយមានភាពបទបែន ក្នុងគោលបំណងបង្កើនមូលធនមនុស្ស និងកម្លាំងពលកម្មជំនាញឱ្យបានកាន់តែច្រើនដើម្បីអាចឆ្លើយតបនឹងតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត។ លើសពីនេះ ក្រសួងនឹងចូលរួមជាមួយក្រសួង-ស្ថាប័នផ្សេងទៀតដើម្បីបណ្តុះបណ្តាលជំនាញដល់យុវជនចំនួន១,៥លាននាក់ ដោយមិនគិតថ្លៃ និងទទួលបានប្រាក់

ឧបត្ថម្ភក្នុងអំឡុងពេលបណ្តុះបណ្តាលស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយក រដ្ឋមន្ត្រី។ ក្រសួងបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ដែល ត្រូវបានរៀបចំឡើងឱ្យស៊ីសង្វាក់គ្នាទៅនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយនេះចំនួនអ្នកមានការងារធ្វើសរុប (អាយុ១៥ឆ្នាំ)បានកើនឡើងពី៨.៦លាននាក់នៅក្នុងឆ្នាំ២០១៥នៅ៩,៦លាននាក់នៅក្នុងឆ្នាំ២០១៨ពោលគឺកើនឡើងប្រមាណជាង ២.៥% ជាមធ្យមក្នុងមួយឆ្នាំ។ ជាមួយនឹងកំណើនការងារវិជ្ជមាននេះអនុបាតអ្នកមានការងារធ្វើនិងប្រជាជន(អាយុ ១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការផ្តល់ការងារដល់ប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការរក្សាបាននូវអត្រាថេរក្នុងរង្វង់ប្រប្រមាណជា៨១% និងអត្រានិកម្មភាព (អាយុ១៥ឆ្នាំ+) ស្ថិតនៅក្នុងអត្រាទាបជាង៩% ក្នុងរយៈពេលដូចគ្នានេះ។ ទន្ទឹមនឹងនេះ គុណភាពនៃការងារក៏ត្រូវបានកែលម្អដែលបង្ហាញតាមរយៈការកើតឡើងនៃបរិមាណភាគនិយោជិតទទួលប្រាក់រូលបានកើតពី ៤៧,៥% នៅក្នុងឆ្នាំ២០១៥ នៅប្រមាណជា៤៨,៨% នៅក្នុងឆ្នាំ២០១៨ ។ បានពង្រីកវិសាលភាពសេវាមុខរបរនិងការងារដោយបង្កើតមជ្ឈមណ្ឌលការងារបន្ថែមចំនួន៦កន្លែងមជ្ឈមណ្ឌលដែលមានស្រាប់ចំនួន៥និងមជ្ឈមណ្ឌលការងារចល័តចំនួន១ព្រមទាំងផ្តល់សេវាប្រឹក្សាយោបល់មុននិងការងារនិងអត្តទេសក៍អាជីពចំនួន៩៩០៨នាក់រៀបចំវគ្គបណ្តុះបណ្តាលត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារចំនួន២៣១វគ្គរៀបចំសិក្ខាសាលាណែនាំអាជីពការងារនិងវិជ្ជាជីវៈតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសកលវិទ្យាល័យចំនួន១០០១ដងព្រមទាំងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីចំនួន៩២នាក់ និងរៀបចំចងក្រងឯកសារអត្តទេសក៍និងការប្រឹក្សាអាជីពការងារ និងវិជ្ជាជីវៈបានអភិវឌ្ឍន៍និងជំរុញការប្រើប្រាស់គេហទំព័រ ទំព័រការងារសម្រាប់ផ្តល់សេវាចុះឈ្មោះអ្នកស្វែងរកការងារនិងជ្រើសរើសកម្លាំងពលកម្មដែលចំនួនចូលប្រើប្រាស់អ្នកចូលរួមប្រើប្រាស់គេហទំព័របានកើតឡើងដល់ប្រមាណជា ១៧ ៨៣២ ២៣៤ លើកព្រមទាំងបង្កើតកម្មវិធីសម្រាប់រកការងារតាមគេហទំព័រ(NEA JobSearch)អ្នកយកមកប្រើប្រាស់សរុបចំនួន៨ ៩២៣ នាក់។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ទោះបីប្រទេសកម្ពុជា ទទួលរងនូវឥទ្ធិពលជម្ងឺកូវីត១៩ក៏ពិតមែន តែកម្ពុជានៅតែអាចងើបឡើង នូវវិស័យសំខាន់ៗជាច្រើនដូចជា វិស័យសុខាភិបាល វិស័យអប់រំនិងបណ្តុះបណ្តាល វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និងវិស័យកសិកម្ម ក្រៅពីវិស័យទាំងនេះក៏នៅមានផងដែរនូវជាតុផ្សំសំខាន់ៗផ្សេងទៀតដែលធ្វើឱ្យកម្ពុជារឹងមាំក្នុងការឈានទៅរកកំណើនសេដ្ឋកិច្ច ។
- វិស័យអប់រំទោះស្ថិតក្នុងដំណាក់កាលរាតត្បាតនៃជំងឺកូវីដ១៩ក៏ពុំបានជាប់គាំងឬរងផលប៉ះពាល់ធ្ងន់ធ្ងរនោះដែរគឺគេអាចរៀនតាមប្រព័ន្ធអនឡាញយ៉ាងមានប្រសិទ្ធភាព។ ក្នុងឆ្នាំ២០២២វិស័យអប់រំក៏បន្តមានតម្រូវការការងារដោយសម្រេចជ្រើសរើសក្របខណ្ឌគ្រូបង្រៀនចំនួន១ ៧១៤នាក់បន្ថែមទៀតផងដែរ។
- វិស័យកសិកម្មបានទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈលំហូរនៃការនាំចេញផលិតផលកសិកម្មជាបន្តបន្ទាប់ទៅកាន់ទីផ្សារអន្តរជាតិពិសេសនៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលធ្វើឱ្យបណ្តាទីផ្សារអន្តរជាតិកាន់តែស្គាល់ច្បាស់ពីគុណភាពផលិតផលកសិកម្មរបស់កម្ពុជា។ ហើយវិស័យនេះនៅតែជាវិស័យសំខាន់ដែលជួយផ្តល់ការងារជូនប្រជាពលរដ្ឋដើម្បីទ្រទ្រង់ជីវភាពរស់នៅ។
- កម្ពុជាមានទំនាក់ទំនងល្អជាមួយវៀតណាមនិងចិនជាពិសេសកម្ពុជាបានធ្វើការទំនាក់ទំនងទៅខាងក្រសួងឧស្សាហកម្មនិងបច្ចេកវិទ្យាព័ត៌មានរបស់ចិនទើបធ្វើឱ្យនៅក្នុងដំណាក់ដែលមានវិបត្តិកូវីដជាសកលកម្ពុជាទទួលបានវត្ថុធាតុដើមមុនគេបំផុតនៅលើពិភពលោក។ទន្ទឹមនឹងនេះនៅឆ្នាំ២០២២មានការបង្កើតនូវរោងចក្រថ្មីចំនួន១១២នៅកម្ពុជាដែលបានបង្កើតការងារដល់ពលរដ្ឋជាង៧ម៉ឺននាក់ និងមានដើមទុនវិនិយោគរហូតដល់ជាង ១ ១៨៩លានដុល្លារសហរដ្ឋអាមេរិក។
- រាជរដ្ឋាភិបាលបានដាក់ចេញនូវសូចនាករកម្រិតយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សុវត្ថិភាពនិងសុខភាពការងារការអភិវឌ្ឍលក្ខខណ្ឌការងារនិងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- ទន្ទឹមនឹងវឌ្ឍនភាពនិងភាពរីកចម្រើន វិស័យកសិកម្ម ក៏បានជួបប្រទះនូវបញ្ហាប្រឈមដូចជាការប្រែប្រួលអាកាសធាតុ ការប្រកួតប្រជែងទីផ្សារនិងទីផ្សារគ្មានស្ថិរភាពថយចុះនៃកម្លាំងពលកម្មផលិតភាពកសិកម្មរបស់កសិករខ្នាតតូចនៅមានកម្រិត ចំណេះដឹងរបស់កសិករផ្នែកបច្ចេកទេសកសិកម្មទំនើបនៅមានកម្រិត ការកើនឡើងថ្លៃដើមផលិត ដូចជា ថ្លៃប្រេង ជីគីមី ថ្លៃដឹកជញ្ជូន ឡូជីស្ទីកឡើងខ្ពស់ជាដើម ។
- ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជាប្រឈមនឹងបញ្ហាដូចជា កង្វះភាពជាអ្នកដឹកនាំ ការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពក្នុងគ្រប់កម្រិតពិសេសការគាំទ្រសំខាន់ៗពាក់ព័ន្ធនឹងឡូជីស្ទីក ធនធានមនុស្សនិងជំនាញ ការអភិវឌ្ឍមូលដ្ឋានចំណេះដឹងផ្នែកបច្ចេកទេសនិងជំនាញការរៀបចំហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅមិនទាន់គ្រប់គ្រាន់នោះទេពិសេសកង្វះការសម្របសម្រួលក្នុងការវិនិយោគលើ

ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត បណ្តាញផ្លូវគមនាគមន៍ លូបញ្ចេញកាកសំណល់ និងការផ្តល់សេវាសាធារណៈឱ្យបានគ្រប់គ្រាន់ ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុនៅមានកម្រិតដែលជាឧបសគ្គដល់ការផ្តល់ហិរញ្ញប្បទានគម្រោងឧស្សាហកម្ម ទាំងយន្តការហិរញ្ញប្បទានសាធារណៈនិងឯកជន បញ្ហាទីផ្សារការងារនិងទំនាក់ទំនងវិជ្ជាជីវៈ ដែលជាគន្លឹះជានាស្ថិរភាពទីផ្សារការងារនិងការផ្គត់ផ្គង់កម្លាំងពលកម្ម ក៏ដូចជាការលើកកម្ពស់ផលិតភាពនិងជីវភាពរបស់ពលករ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយការសិក្សានិងស្រាវជ្រាវកន្លងមក យើងបានពិនិត្យមើលឃើញថា តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា មានសន្ទុះនៃការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ សម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ តម្រូវការទីផ្សារការងារ គឺជាសសរគ្រឹះដ៏សំខាន់ក្នុងការកាត់បន្ថយភាពអត់ការងារធ្វើរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស មិនថានិស្សិតដែលបានសិក្សា ឬប្រជាជនដែលបានសិក្សាតិចនោះទេពួកគេមានទីផ្សារការងារ និងដើម្បីអភិវឌ្ឍន៍ប្រទេសឱ្យមានភាពជឿនលឿន និងកាន់តែសម្បូរបែបថែមទៀត ។ ដូច្នេះការជំរុញឱ្យនិស្សិត ក៏ដូចប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសមានការងារធ្វើ គឺជាកត្តាចម្បងសម្រាប់រាជរដ្ឋាភិបាលដើម្បីសម្រេចតាមផែនការដែលបានដាក់ចេញរបស់រដ្ឋាភិបាល ។

ឆ្លងតាមការសិក្សាស្រាវជ្រាវកន្លងមកនេះ ក្រុមនាងខ្ញុំអាចសន្និដ្ឋានបានថាតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជាទាំងមូលក្នុងការចូលរួមចំណែកពង្រឹងប្រព័ន្ធព័ត៌មានទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែមានដំណើរការរីកចម្រើន និងជួយផ្តល់ព័ត៌មានអំពី ស្ថានភាពទីផ្សារការងារនាពេលបច្ចុប្បន្នដល់ប្រជាជនកម្ពុជា ដើម្បីត្រៀមខ្លួនយ៉ាងល្អប្រសើរសមស្របទៅនឹងតម្រូវការទីផ្សារការងារ ។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ « តម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននៅកម្ពុជា » រួចមកបានបង្ហាញឱ្យឃើញថា ប្រទេសកម្ពុជាមានការរីកចម្រើនទៅលើគ្រប់វិស័យពីសម័យកាលមួយទៅសម័យកាលមួយទៀត ព្រមទាំងផ្តល់ទីផ្សារការងារល្អៗសម្រាប់ប្រជាជនកម្ពុជា ដែលអាចជួយកាត់បន្ថយភាពក្រីក្រផងដែរ ។

ប៉ុន្តែទន្ទឹមនឹងការរីកចម្រើនរីកនេះផងដែរក៏នៅមានឃើញចំណុចមួយចំនួនតូចដែលយើងមានគំនិតនិងយោគបល់បន្ថែមក្នុងន័យស្ថាបនាដូចខាងក្រោម ៖

១.ចំពោះវិស័យកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទគួរតែពង្រឹងបន្ថែមនូវលទ្ធភាពក្នុងការស្វែងរកទីផ្សារជូនទៅដល់ប្រជាកសិករ លើកកម្ពស់ផលិតភាពកសិកម្មរបស់កសិករ បង្កើនថែមនូវវគ្គបណ្តុះបណ្តាលផ្នែកកសិកម្មទំនើប និងពង្រឹងការដាំដុះដើមឈើដើម្បីអាចកាត់បន្ថយនូវការបម្រែបម្រួលអាកាសធាតុ ឬគ្រោះធម្មជាតិផ្សេងៗ ។

២.សេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងដំណាក់កាលប្រែប្រួលសំខាន់មួយ ក្រោយពីសម្រេចបានកំណើនខ្ពស់ក្នុងរយៈពេលជាងមួយទសវត្សមកនេះ ពោលគឺការឈានឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមដែលតម្រូវឱ្យ មានការកែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ សំដៅពង្រឹងពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែងដែលធានាបាននូវកំណើនសេដ្ឋកិច្ចដែលប្រកបដោយចីរភាពនិងមានការបែងចែកផ្លែផ្កាប្រកបដោយសមធម៌

ប្រការនេះទាមទារឱ្យមានការគិតគូរអំពីអភិក្រមអភិវឌ្ឍថ្មីបន្ថែម ពាក់ព័ន្ធនឹងការពង្រីកកាលានុវត្តអភិវឌ្ឍ និងការវិនិយោគក្នុងវិស័យកំណើនថ្មី ពិសេសតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមចាំបាច់ ការផ្គត់ផ្គង់ថាមពលអគ្គិសនី ការពង្រីកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងការអភិវឌ្ឍប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ចំណេះដឹងផ្នែកបច្ចេកទេសនិងវិទ្យាសាស្ត្រ និងការពង្រឹងយន្តការស្ថាប័នប្រកបដោយសមត្ថភាពនិងមានប្រសិទ្ធភាព។

# ឯកសារយោង

# ឯកសារយោង


- វេចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត
- mlvt.gov.kh
- ams.com.kh
- tvjlc.com
- construction-property.com
- https://cdc.gov.kh/wp-content/uploads/2022/04/IDP-Khmer.pdf
- https://cambonomist.com/news/working-conditions-in-the-world/
- https://www.minimumwage.gov.kh/7603/
- https://www.mlvt.gov.kh/index.php?option=com_k2&view=item&layout=item&id=13&Itemid=103&lang=km
- https://www.cambodianbudget.org/filestinymce/New_Pic/Development_Policies/Sectoral_Policies/Strategic_Plan_on_Technical_and_Vocational_Education_Training_Development_2014-2018_Kh.pdf
- https://cnc.com.kh/detail/news/28846
- https://economy.ams.com.kh/finance/news/the-insurance-sector-in-cambodia-is-still-young-and-demands-the-mainstreaming-of-knowledge/
- https://www.information.gov.kh/articles/87710
- https://kh.cc-times.com/posts/12051
- https://construction-property.com/km/mef-construction-is-forecasted-to-recover-only-3-in-2022/
- https://economy.ams.com.kh/economic/news/cambodias-textile-and-garment-sector-maintains-strong-growth/
- https://opendevelopmentcambodia.net/km/news/cambodias-rubber-goods-exports-up-28-in-2022/#!/story=post-169993
- https://opendevelopmentcambodia.net/km/news/nearly-400-million-earned-by-cambodia-in-10-months-through-rubber-rubber-wood-exports/#!/story=post-167537
- https://www.cpp.org.kh/details/334764
- https://www.information.gov.kh/articles/107268
- https://www.cpp.org.kh/details/320026
- https://m.freshnewsasia.com/index.php/en/localnews/332346-2024-03-14-03-21-19.html

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ




AMS
ព្រឹត្តិការណ៍ព័ត៌មាន
ចំណេះជីវិត
ជំនាញ
យុវជនឆ្នើម
អប់រំកុមារតូច
ព័ត៌មានអាហារូបករណ៍
អនាគត
ពន្លកបៃតង
កម្ពុជា 360°
មាតិកាឌីជីថល:
NEWS
ទំព័រដើម › ព្រឹត្តិការណ៍ › ព័ត៌មានជាតិ និងអន្តរជាតិ › ព័ត៌មានជាតិ › វិស័យអប់រំត្រូវមានផែនការបាញ់ឆ្ពោះទៅលើកស្ទួយសេដ្ឋកិច្ចជាតិ
ព័ត៌មានជាតិ / ព័ត៌មានអន្តរជាតិ
ប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាម ៖ ក្នុងមួយថ្ងៃកម្ពុជាត្រូវការឈាម ១៤ម៉ឺនប្លោក
លោកជំទាវ តិមា រិទ្ធិកាល ៖ ការផ្តល់ឈាមសង្គ្រោះជីវិត ជាកាយវិការដ៏ប្រពៃ






ស្វែងរក ...

Like Share Be the first of your friends to like this.

ថ្ងៃព្រហស្បតិ៍, 22 ខែធ្នូ, 2022 អត្ថបទដោយ MET KIMAU

(ភ្នំពេញ)៖ ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានដាក់ចេញនូវអនុសាសន៍ណែនាំបន្ថែម ចំនួន៥ចំណុច ដល់សមាគមទេសចរណ៍កម្ពុជា (CATA) ដើម្បីជាធាតុចូលសម្រាប់សកម្មភាពការងាររបស់សមាគម នាឆ្នាំ២០២៣ខាងមុខនេះ និងឆ្នាំបន្តបន្ទាប់ទៀត សំដៅធ្វើយ៉ាងណាឱ្យការអនុវត្តន៍ការងារកាន់តែទទួលបានភាពជោគជ័យ។

**កម្មវិធីនយោបាយ**
**របស់គណបក្សប្រជាជនកម្ពុជាសម្រាប់**
**ការកសាង និងការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨**

កម្មវិធីមើលព័ត៌មានតាមទូរស័ព្ទ



AD HERE
350 x 150




## ក្រសួងពាណិជ្ជកម្មជំរុញលើកទឹកចិត្តដល់សិស្សនិស្សិតកម្ពុជាឲ្យខិតខំសិក្សាស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថលនិងនវានុវត្តន៍ឧស្សហកម្ម៤.០និងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិច ត្រូនិក

TVJLC ២៦ សីហា ២០២២

### ព័ត៌មានថ្មីៗ


សម្តេចធិបតីហ៊ុនម៉ាណែតក្នុងឱកាសប្រារព្ធទិវាជាតិសហគ្រាសធុនមីក្រូតូចនិងមធ្យ ម លើកទី1ថ្ងៃទី27ខែមិថុនាឆ្នាំ2024


ចាប់ពីថ្ងៃ25ដល់ថ្ងៃទី27ខែមិថុនាតាមបណ្តាខេត្តនិងភ្នំពេញអាចមានភ្លៀងធ្លាក់ជាមួយផ្គររន្ទះនិងខ្យល់កន្ត្រាក់បោកបក់គ្របដណ្តប់លើផ្ទៃដី20%


សមត្ថកិច្ចឃាត់ខ្លួនមនុស្ស77នាក់ក្នុងប ទល្មើសព្រហ្មទណ្ឌនិងបទល្មើសគ្រឿងញៀន


ស្លាប់1នាក់និងរបួសធ្ងន់ស្រាល3នាក់ក្នុង ករណ
គ្រោះថ្នាក់ចរាចរណ៍ចំនួន4លើក

https://cambonomist.com/news/working-conditions-in-the-world/




ស្ថានភាពការងារនៅលើពិភពលោក

# តើស្ថានភាពការងារនៅលើពិភពលោកនឹងប្រែប្រួលយ៉ាងណាក្នុងរយៈពេល ៥ ឆ្នាំទៀត?

ចាប់ពីពេលនេះរហូតដល់ឆ្នាំ ២០២៧ ស្ថានភាពទីផ្សារនិងបរិយាកាសការងារនៅលើពិភពលោកនឹងប្រែប្រួលគួរឲ្យកត់សំគាល់។ ការស្ទង់មតិមួយដែលគេបានធ្វើជាមួយបណ្ដានិយោជក និង បានចេញផ្សាយនៅថ្ងៃចន្ទ ខែឧសភាឆ្នាំនេះ បង្ហាញឱ្យឃើញដូច្នេះ។ វេទិកាសេដ្ឋកិច្ចពិភពលោកដែលគេបានស្គាល់តាមរយៈការរៀបចំវេទិកាសេដ្ឋកិច្ចប្រចាំឆ្នាំនៅទីក្រុងដាវ៉ូស ប្រទេសស្វីស ជាអ្នកបញ្ចេញលទ្ធផលនៃការស្ទង់មតិនោះ។ នេះបើយោងតាមសារព័ត៌មាន អិនខ្វៃអើរី (Inquirer)។

https://www.minimumwage.gov.kh/7603/

# គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ៖ បង្កើនឱកាសការងារសមរម្យ លើកម្ពស់ជំនាញវិជ្ជាជីវៈ និងពង្រឹងអភិបាលកិច្ចទីផ្សារការងារ

ថ្ងៃព្រហស្បតិ៍, 26 ខែសីហា, 2021 1293

ពេញ)៖គណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ នាព្រឹកទី២៦ ខែសីហា ឆ្នាំ២០២១នេះ បានបើកកិច្ចប្រជុំលើកទី៥របស់ខ្លួន តាមប្រព័ន្ធវីដេអូ (Zoom) ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ ងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥។




https://www.mlvt.gov.kh/index.php?option=com_k2&view=item&layout=item&id=13&Itemid=103&lang=km
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
MINISTRY OF LABOUR AND VOCATIONAL TRAINING
ភាសាខ្មែរ
English
Search
អំពីក្រសួង
គោលនយោបាយ និងផែនការ
ទស្សនាវដ្តី និងព្រឹត្តិបត្រ
ឯកសារផ្លូវការ
ទំនាក់ទំនង
សេវាសាធារណៈ
សៀវភៅ/បណ្ណការងារសម្គាល់កម្មករនិយោជិតខ្មែរ
សេវាពេទ្យការងារ
បញ្ជិកាគ្រឹះស្ថានបណ្តុះបណ្តាល
សេវាហត្ថកម្មបរទេស
ស្វ័យប្រកាសអធិការកិច្ចការងារ
ធ្វើការងារក្រៅប្រទេស
តាមដានវឌ្ឍនភាពសេវាសាធារណៈក្រសួង
សេវាផ្សេងៗ
អំពីក្រសួង
ពុធ, 10 កុម្ភៈ 2016 15:28 | Written by MLVT | 144013 times | Print | Email
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ក្នុងនីតិកាលទី៣ នៃរដ្ឋសភា ស្របតាមអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ
និងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ប៉ុន្តែនៅឆ្នាំ២០១៤ ត្រូវបានរៀបចំធ្វើវិសោធនកម្ម តាមរយៈអនុក្រឹត្យលេខ២៨៣អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ


CNC
ទំព័រដើម
ព័ត៌មានជាតិ
សន្តិសុខសង្គម
អន្តរជាតិ
កីឡា
សុខភាព
វីដេអូ
ព័ត៌មាន ថ្មីៗ
សម្តេចតេជោ ហ៊ុន សែន ប្រាប់សមាជិកព្រឹទ្ធសភាជប៉ុនថាសម្តេចប្រកាន់ខ្ជាប់នូវទស្សនៈផ្តល់តម្លៃដល់សន្តិភាពគ្មានថ្ងៃប្រែប្រួល
សង្គម
រដ្ឋមន្ត្រីក្រសួងសុខាភិបាល ៖ វិស័យសុខាភិបាល ជាវិស័យអាទិភាពមួយ ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការ អភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា
១៦-មីនា-២០២២ ១០:២៨ ព្រឹក 375 Share
ដើម្បីទទួលព័ត៌មានថ្មីៗ
FACEBOOK
TELEGRAM
YOUTUBE
WEBSITE
ទាញកម្មវិធី
CNC HOT NEWS
App Store
Play Store
តាមដានបច្ចុប្បន្នភាព
នៃព្រឹត្តិការណ៍ព័ត៌មានជាតិ
និង ព័ត៌មានអន្តរជាតិតាមរយៈ
Mobile App របស់ CNC

ក្រសួងព័ត៌មាន

ប្លែក លឿន ទុកចិត្តបាន ពេលណា ទីណាក៏បាន

ំព័រដើម